# “ខ្ញុំ រៀបការជាមួយនឹងបុរស ដើម្បីបំពេញចិត្ត ឪពុកម្ដាយរបស់ខ្ញុំ”



## អំពើហិង្សាគ្រួសារប្រឆាំងនឹងស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស នៅក្នុងប្រទេសកម្ពុជា

អង្គការសហគមន៍ឥន្ទធនូកម្ពុជា
RUCK
RAINBOW COMMUNITY KAMPUCHEA ORGANISATION

មិថុនា ឆ្នាំ២០១៩

# “ខ្ញុំរៀបការជាមួយនឹងបុរស ដើម្បីបំពេញចិត្ត ឪពុកម្ដាយរបស់ខ្ញុំ”

## របាយការណ៍អំពើហិង្សាគ្រួសារប្រឆាំងនឹងស្ត្រីស្រឡាញ់ស្ត្រី
## ស្ត្រីស្រឡាញ់ទាំងពីរភេទ
## និងស្ត្រីប្តូរយេនឌ័រជាបុរស នៅក្នុងប្រទេសកម្ពុជា

ខែមិថុនា ឆ្នាំ២០១៩

អង្គការសហគមន៍ឥន្ទធនូកម្ពុជា(រ៉ក់)

*សេចក្តីថ្លែងអំណរគុណ*

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណទៅដល់ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសទាំងអស់(LBT) ដែលបានចូលរួមជាមួយការសិក្សាស្រាវជ្រាវមួយនេះ តាមរយៈការចែករំលែកនូវរឿងរ៉ាវជីវិតផ្ទាល់ខ្លួន។ ការសិក្សាស្រាវជ្រាវនេះនឹងមិនអាចប្រព្រឹត្តិទៅបាននោះទេ ប្រសិនបើគ្មានការអនុញ្ញាតប្រកបដោយសមានចិត្តនិងឆន្ទៈក្នុងការចែករំលែកនូវរាល់បទពិសោធន៍ទាំងអស់របស់ពួកគេ។ ជាមួយគ្នានេះ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ស្ថាប័នពាក់ព័ន្ធមកពីអាជ្ញាធររាជរដ្ឋាភិបាលកម្ពុជា ភ្នាក់ងារសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសាស្ត្រាចារ្យ ដែលបានចូលរួមផ្តល់នូវទស្សនទានផ្ទាល់ខ្លួនប្រកប ដោយវិជ្ជាជីវៈទាក់ទងនឹងបញ្ហារបស់ ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសទាំងអស់នៅក្នុងប្រទេសកម្ពុជា។

របាយការណ៍នេះគឺជាសមិទ្ធផលស្តែងចេញពីការខិតខំប្រឹងប្រែងយ៉ាងសកម្មរវាងបុគ្គលិកនិងក្រុមប្រឹក្សាភិបាលរបស់អង្គការសហគមន៍ឥន្ទធនូកម្ពុជា(រ៉ក់) ក្រុមស្រាវជ្រាវដែលដឹកនាំដោយ លោកស្រី កាស៊ូមី ណាកាហ្កាវ៉ា ជាសាស្ត្រាចារ្យផ្នែកយេនឌ័រនៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ហើយនិងក្រុមការងារគឺ លោក លាន ធវន្តែ កញ្ញា សាយ ស៊ីសូម៉ា កញ្ញា ម៉ូនីល័ក្ខ សុគន្ធីការ កញ្ញា នូ សម្បត្តិ និងព្រះតេជគុណ ម៉ន មេងអៀន។

ខ្ញុំសូមថ្លែងអំណរគុណជាពិសេសដល់ក្រុមត្រួតពិនិត្យរបាយការណ៍នេះរួមមាន លោកស្រី ចាន់ គន្ធា លោកស្រី ហ៊ុន បូរាមី លោកស្រី ខលឡិត អូរីហ្គាន់(Collette O’Regan) កញ្ញា សេលីន ម៉ាទីន(Céline Martin) កញ្ញា ខេត ស៊ីវេលដ៍(Kate Seewald) លោក ផាត់ ឌឺ ប្រ៊ុន(Pat de Brún) សាស្ត្រាចារ្យ រេឆិល បារ៉ាត់(Rachael Barat) និងបុគ្គលិកគម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ នៃអង្គការមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(ម.ស.ម.ក)។ ខ្ញុំក៏សូមថ្លែងសេចក្តីអំណរគុណដល់ លោក លាន ធវន្តែ ដែលបានរួមចំណែកក្នុងការប្រែសម្រួលរបាយការណ៍ស្រាវជ្រាវនេះពី ភាសាអង់គ្លេសមក ជាភាសាខ្មែរ។

ខ្ញុំសង្ឃឹមថារបាយការណ៍នៃការសិក្សាស្រាវជ្រាវស្តីពី"អំពើហិង្សាគ្រួសារប្រឆាំងនឹងស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស នៅក្នុងប្រទេសកម្ពុជា" នឹងក្លាយជាសក្ខីកម្មនិងជាទស្សនទានប្រកបដោយគុណតម្លៃមួយសម្រាប់ជាទុនក្នុងការដឹកនាំរៀបចំឲ្យមានសកម្មភាពផ្សេងទៀតនាពេលអនាគត ក្នុងការចូលរួមស្វែងរកដំណោះស្រាយ និងតម្លាភាពឆ្លើយតបទៅនឹងភាពអយុត្តិធម៌ អំពើហិង្សាលើយេនឌ័រ និងអំពើហិង្សាក្នុងគ្រួសារប្រឆាំងនឹងក្រុមងាយរងគ្រោះ បង្កឡើងដោយសមាជិក គ្រួសារ ដោយសារកត្តានិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័ររបស់បុគ្គល។ អង្គការរ៉ក់ មានគោលជំហរយ៉ាងមុតមាំក្នុងការស្នើឲ្យអាជ្ញាធររាជរដ្ឋាភិបាលកម្ពុជា អង្គការជាតិនិងអន្តរជាតិ ស្ថាប័នអប់រំ និងដៃគូអភិវឌ្ឍឲ្យបន្តចូលរួមតស៊ូមតិក្នុងការគាំពារសិទ្ធិនិងសេរីភាពរបស់ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស ដើម្បីឲ្យពួកគេអាចរស់នៅក្នុងសង្គមជៀសផុតពីការរើសអើង និងអំពើហិង្សាគ្រប់រូបភាពទាំងអស់។

**លី ពិសី**

**អ្នកសម្របសម្រួលអង្គការសហគមន៍ឥន្ទធនូកម្ពុជា**

# មាតិកា


សេចក្តីថ្លែងអំណរគុណ ..... III

សេចក្តីសង្ខេប ..... 1

របកគំហើញសំខាន់ៗ ..... 2

១.សេចក្តីផ្តើម៖ អំពើហិង្សាគ្រួសារប្រឆាំងនឹងស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស (LBT) ..... 4

២. អំពើហិង្សាបង្កដោយសមាជិកគ្រួសារ ..... 6

២.១. អំពើហិង្សាក្នុងគ្រួសារ គឺជាទម្រង់អំពើហិង្សាដ៏ឃោរឃៅបំផុតសម្រាប់ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស ..... 8

២.២. អំពើហិង្សាលើផ្លូវចិត្តបង្កដោយសមាជិកគ្រួសារ ..... 9

២.៣. អំពើហិង្សាលើផ្លូវកាយបង្កដោយសមាជិកគ្រួសារ ..... 11

២.៤. អំពើហិង្សាលើផ្លូវភេទ ..... 13

២.៥. អំពើហិង្សាផ្នែកសេដ្ឋកិច្ច ..... 14

៣. “ខ្ញុំដឹងថា គ្មាននរណាម្នាក់ចង់ធ្វើដូចជាខ្ញុំទេ” ផលប៉ះពាល់ពីអំពើហិង្សា ..... 16

៤. “ខ្ញុំបានព្យាយាមហើយ ប៉ុន្តែ.....”៖ វិធីសាស្ត្រការពារខ្លួន ឬ ទបទល់ ..... 16

៥. “កូនស្រីខ្ញុំមិនស្តាប់តាមបង្គាប់របស់ខ្ញុំសោះ” មូលហេតុនៃអំពើហិង្សា ..... 18

៥.១. អំពើហិង្សាដោយសារភាពអាម៉ាស់ ..... 18

៥.២. អំពើហិង្សាដោយសារបទដ្ឋានយេនឌ័រនិងសង្គមដែលតឹងរ៉ឹងសម្រាប់ក្មេងស្រី និងស្ត្រីនៅក្នុងសង្គមកម្ពុជា ..... 19

៥.៣. អំពើហិង្សាដែលកើតឡើងពីការយល់ដឹងនូវមានកម្រិតអំពីភាពចម្រុះនៃផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ ..... 20

៦. អនុសាសន៍ ..... 20

**៧. សេចក្ដីសន្និដ្ឋានៈ ពហុប្រព័ន្ធនៃការគាបសង្កត់**........................................................................ 24

ឧបសម្ព័ន្ធទី១ គោលបំណង គោលដៅ និងមធ្យោបាយក្នុងការសិក្សាស្រាវជ្រាវ................................... 26

*ចំណាំៈ ឈ្មោះអ្នកទាំងអស់ដែលប្រើនៅក្នុងករណីសិក្សានៃការសិក្សាស្រាវជ្រាវនេះគឺជាឈ្មោះគេដាក់ឱ្យ។*

*សេចក្តីសង្ខេប*

ការស្រាវជ្រាវមួយនេះ គឺជាការសិក្សាលើកដំបូង ដែលបានធ្វើការចងក្រងប្រមូលផ្តុំនូវរាល់រឿងរ៉ាវបទពិសោធន៍បញ្ហាផ្ទាល់ខ្លួនទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារប្រឆាំងទៅនឹងស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសនៅក្នុងប្រទេសកម្ពុជា។ មានស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរ និងស្ត្រីប្តូរយេនឌ័រជាបុរស ជាច្រើនកំពុងប្រឈមនឹងការរើសអើងនិងអំពើហិង្សាបណ្តាលមកពីកត្តានិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ។ ការសិក្សាស្រាវជ្រាវនេះផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើទម្រង់នៃអំពើហិង្សាបង្កឡើងដោយសមាជិកគ្រួសារ ដែលជាបញ្ហាត្រូវបានមជ្ឈដ្ឋានទូទៅមើលរំលងឬមិនទទួលបានការអើពើក្នុងសង្គមនាពេលបច្ចុប្បន្ន។

ការសិក្សាស្រាវជ្រាវមួយនេះ បានរៀបចំធ្វើការសិក្សាដោយក្រុមអ្នកស្រាវជ្រាវឯករាជ្យ ដឹកនាំដោយលោកស្រី កាស៊ូមី ណាកាហ្គាវ៉ា ជាសាស្ត្រាចារ្យផ្នែកយេនឌ័រនៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា។ បុគ្គលិករបស់អង្គការសហគមន៍ឥន្ទធនូកម្ពុជាបានផ្តល់មូលនិធិ ការសម្របសម្រួលលើការងារបច្ចេកទេស និងការងារស្នូលមួយចំនួន ដែលបានបង្កលក្ខណៈងាយស្រួលដល់ដំណើរការវិភាគទិន្នន័យ ដើម្បីផលិតចេញជារបាយការណ៍មួយនេះឡើង។

ការសិក្សាស្រាវជ្រាវនេះបានចាប់ផ្តើមពីខែកុម្ភៈ ដល់ខែមេសា ឆ្នាំ២០១៩។ ក្រុមអ្នកស្រាវជ្រាវបានជួបសម្ភាសន៍ជាមួយស្ត្រីស្រឡាញ់ស្ត្រីចំនួន ២៣នាក់ ស្ត្រីស្រឡាញ់ទាំងពីរភេទចំនួន០៤នាក់ និងស្ត្រីប្តូរយេនឌ័រជាបុរសចំនួន ៣៤នាក់ ដែលសរុបមានចំនួន៦១នាក់ នៅក្នុងខេត្តចំនួន ០៨។ ក្នុងចំណោមនោះ ៥១% ស្មើនឹង៣១នាក់ មានអាយុក្រោម៣៥ឆ្នាំ។ លើសពីនេះទៀត ក្រុមអ្នកស្រាវជ្រាវក៏បានសុំសម្ភាសន៍ជាមួយឪពុកម្តាយរបស់ពួកគាត់ចំនួន ០៤នាក់ អាជ្ញាធរនិងមន្ត្រីរាជរដ្ឋាភិបាលចំនួន ០៨នាក់ បុគ្គលិកភ្នាក់ងារអង្គការសហប្រជាជាតិចំនួន ០៣នាក់ សាស្ត្រាចារ្យចំនួន ០៣នាក់ និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលចំនួន ០៣នាក់។

*របកគំហើញសំខាន់ៗ*

ស្ថានភាពអំពើហិង្សាក្នុងគ្រួសារលើស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសបង្កដោយសមាជិកក្នុងគ្រួសារត្រូវបានរកឃើញថាមានកម្រិតខ្ពស់រហូតដល់៨១% នៃអ្នកដែលមានអាយុក្រោម៣៥ឆ្នាំ។ ការសិក្សាស្រាវជ្រាវក៏បានរកឃើញដែរថា ស្ថានភាពនៃអំពើហិង្សាដែលបង្កឡើងដោយសមាជិកក្នុងគ្រួសារជាបញ្ហាធ្ងន់ធ្ងរ ដែលអាចផ្តល់ផលអវិជ្ជមានដល់ជីវិតរបស់ ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសផ្ទាល់ បើប្រៀបធៀបទៅនឹងអំពើហិង្សាដែលបង្កឡើងដោយមជ្ឈដ្ឋានខាងក្រៅ។

**របកគំហើញសំខាន់ៗ៖**

- ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស ចំនួន៨១% អាយុក្រោម៣៥ឆ្នាំ ជួបប្រទះអំពើហិង្សាលើផ្លូវចិត្ត។
- ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសចំនួន ១០% ដែលស្មើនឹង ៦ នាក់ ជួបប្រទះនឹងអំពើហិង្សាផ្លូវភេទ ដែលជាធម្មតាកើតឡើងដោយសារការបង្ខំឲ្យរៀបការជាមួយបុរស
- ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស ដែលមានអាយុក្រោម៣៥ឆ្នាំ ចំនួន៣៥% នៃមនុស្ស៣១នាក់ មានពេលខ្លះធ្លាប់គិតចង់សម្លាប់ខ្លួននិងធ្លាប់សម្លាប់ខ្លួនហើយ តែមិនបានសម្រេច ដោយសារតែការបដិសេធរបស់គ្រួសាររបស់ពួកគាត់ចំពោះ និន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ។

ការបាក់ទឹកចិត្តនិងការត្រូវបានមើលងាយ កើតមានជាទូទៅចំពោះស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស។

**អំពើហិង្សាលើផ្លូវចិត្ត៖** ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសភាគច្រើន(៨១% នៃ២៥នាក់) ដែលមានអាយុក្រោម ៣៥ឆ្នាំ ធ្លាប់ជួបប្រទះអំពើហិង្សាលើផ្លូវចិត្ត ដែលទន្ទឹមនឹងនោះជារឿយៗពួកគាត់ក៏ទទួលរងនូវទម្រង់នៃអំពើហិង្សាផ្សេងទៀតផងដែរដូចជា វាយដំ ដកហូតទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងបំបិទសិទ្ធិសេរីភាពផ្ទាល់ខ្លួន។ តាំងពីដំណាក់កាលនៃការចាប់ផ្តើមបញ្ចេញនូវនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ឬការបង្ហាញយេនឌ័ររបស់ខ្លួន សមាជិកគ្រួសារចាប់ផ្តើម និយាយពាក្យសម្តីធ្ងន់ៗពី ស្ត្រីស្រលាញ់ស្ត្រី ស្ត្រីស្រលាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស ដែលធ្វើឲ្យកូនលែងហ៊ានចេញមុខជាចំហរ។ នៅពេលពួកគេបញ្ចេញនូវនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ឬការបង្ហាញយេនឌ័រជាចំហ ពួកគេទទួលរងនូវការវាយប្រហារធ្ងន់ធ្ងរទៅលើផ្លូវចិត្ត ដោយរាប់បញ្ចូលទាំងការរើសអើងមិនត្រូវទទួលស្គាល់វត្តមានរបស់ខ្លួន ជាសមាជិកម្នាក់នៅក្នុងក្រុមគ្រួសារ។

**អំពើហិង្សាលើផ្លូវកាយៈ** ការសិក្សាស្រាវជ្រាវបានរកឃើញថា មានស្ត្រីប្តូរយេនឌ័រជាបុរសចំនួន ០២នាក់ និងស្ត្រីស្រឡាញ់ស្ត្រីចំនួន ០២នាក់ បានរាយការណ៍ថាធ្លាប់ទទួលរងគ្រោះធ្ងន់ធ្ងរដោយសារការវាយដំលើរូបរាងកាយបង្កដោយសមាជិកគ្រួសាររបស់ខ្លួន។ គ្រួសាររបស់ពួកគាត់ធ្វើបែបនេះ គឺដើម្បី "**កែប្រែ**" ឲ្យពួកគាត់ប្រតិបត្តិទៅតាម "**តួនាទីយេនឌ័រជាស្ត្រី**" ដែលមានស្រាប់នៅក្នុងសង្គម។

**អំពើហិង្សាលើផ្លូវភេទៈ** ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសចំនួន ០៦នាក់ បានរាយការណ៍ថា ពួកគាត់ត្រូវបានបង្ខំឲ្យរៀបការជាមួយបុរស។ ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសចំនួន ០២នាក់ ក៏បានរាយការណ៍ផងដែរថា ពួកគាត់រៀបការជាមួយបុរសដើម្បីបំពេញតាមបំណងប្រាថ្នារបស់ឪពុកម្តាយ( ដោយលាក់បាំងអំពីនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ឬការបង្ហាញយេនឌ័រពិតប្រាកដរបស់ខ្លួន។

**អំពើហិង្សាលើសេដ្ឋកិច្ចៈ** ដោយសារតែឪពុកម្តាយមានអំណាចផ្នែកហិរញ្ញវត្ថុ ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស ត្រូវបានដកហូតទ្រព្យសម្បត្តិមិនឲ្យប្រើប្រាស់ ឬចាយវាយ ឬមិនបង់ថ្លៃសាលាឲ្យ។

## ឫសគល់នៃអំពើហិង្សា

ឫសគល់នៃអំពើហិង្សាពីសមាជិកគ្រួសាររបស់ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ ស្ត្រីប្តូរយេនឌ័រជាបុរសអាចមានលក្ខណៈខុសគ្នាដោយសារកត្តាផ្សេងៗដូចជា អ្នកដែលអនុវត្តការប្រៀនប្រដៅកូនតាមវិធីបុរាណតាមផ្នត់គំនិតសង្គម តាមសាសនា និង/ឬតាមលក្ខណៈជនជាតិ។

- ឪពុកម្តាយនៅប្រទេសកម្ពុជាមានអារម្មណ៍ថាអាម៉ាស់ជាខ្លាំងនៅពេល ដែលកូនស្រីរបស់ពួកគាត់មិនអនុវត្តតាមតួនាទីយេនឌ័រ ដែលប្រពៃណីនិងវប្បធម៌សង្គមកំណត់ឲ្យ ក្នុងភាពជាក្មេងស្រីឬស្ត្រី ហើយពួកគាត់ប្រើអំពើហិង្សាទៅលើកូនរបស់ពួកគាត់ ដើម្បីលុបបំបាត់ក្តីអាម៉ាស់ទាំងនោះ។
- ឪពុកម្តាយរបស់ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ ស្ត្រីប្តូរយេនឌ័រជាបុរស ត្រូវទទួលរងនូវឥទ្ធិពលនៃផ្នត់គំនិតសង្គមនិងយេនឌ័រនៅក្នុងសង្គមខ្មែរហើយពួកគាត់ព្យាយាម "កែប្រែ" អត្តសញ្ញាណយេនឌ័រកូនៗរបស់ពួកគាត់ឲ្យស្របនឹងភេទពីកំណើត។
- ឪពុកម្តាយជាច្រើនមិនបានយល់ដឹងអំពីភាពចម្រុះនៃភេទនិងអត្តសញ្ញាណយេនឌ័រនោះទេ ហើយពួកគាត់ឃើញ "ភាពផ្សេងគ្នា" រវាងកូនពួកគាត់និងក្មេងស្រីដទៃ គាត់អាចរិះគន់ដោយមិនបានពិចារណា។

### នរណាជាស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស?

ការសិក្សាស្រាវជ្រាវនេះ បានផ្តោតលើស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស(LBT) ដែលជាអ្នកដែលមានអត្តសញ្ញាណភេទជាស្រីពីកំណើត ប៉ុន្តែពួកគេមិនអាចអនុលោមទៅតាមតួនាទីយេនឌ័រដែលសង្គមកំណត់ឲ្យ ដោយសារតែនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័ររបស់ខ្លួន។ សូមធ្វើការកត់សំគាល់ផងដែរថា LBT ពុំស្ថិតនៅក្នុងក្រុមតែមួយដូចគ្នានោះទេ ប៉ុន្តែពួកគេគឺមានលក្ខណៈចម្រុះ។ ដូច្នេះនៅក្នុងការសិក្សានេះ បុគ្គលម្នាក់ៗបានកំណត់អត្តសញ្ញាណយេនឌ័រដោយខ្លួនឯងផ្ទាល់ថា "ពួកគាត់ជានរណា"។ ប៉ុន្តែ ពាក្យស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស(LBT) ត្រូវបានប្រើជារួមសម្រាប់ពិពណ៌នា អ្នកដែលបានចូលរួមសរុប ៦១នាក់ នៅក្នុងការសិក្សាស្រាវជ្រាវនេះ។

## *១.សេចក្តីផ្តើម៖ អំពើហិង្សាគ្រួសារប្រឆាំងនឹងស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស (LBT)*

ចិត្រា អាយុ ២៤ឆ្នាំ ជាស្ត្រីស្រឡាញ់ស្ត្រី ធ្លាប់ត្រូវបានទទួលការរិះគន់ថាជា "មនុស្សវិកលចរិត" ក្រោយពេល មិត្តរបស់នាងបានដឹងអំពីទំនោរឬនិន្នាការភេទពិតប្រាកដរបស់នាង។ មិត្តភក្តិទាំងអស់របស់នាងក៏បាននាំគ្នាសម្រេចចិត្តផ្តាច់ការទាក់ទងជាមួយនាង ហើយហាមនាងមិនឲ្យបន្តដើរជាមួយមិត្តភក្តិនៅក្នុងក្រុមតទៅទៀតទេ ព្រោះតែមិត្តភក្តិរបស់នាងគិតថា "**នាងជាមនុស្សចម្លែក**"។ ស្ថិតក្នុងស្ថានភាពពិបាកបែបនេះ ការរស់នៅ ក្នុងផ្ទះលែងមានភាពកក់ក្តៅទៀតហើយ នាងបាននិយាយថា "ស្ទើរតែរាល់ពេលទៅហើយដែលឪពុកម្តាយរបស់នាងតែងតែនិយាយដើមកូនស្រីរបស់អ្នកជិតខាងដែលមានទំនោរភេទដូចនាង ដោយម្តាយរបស់នាងបាននិយាយថា *"ប្រសិនបើយើងមានកូនបែបនោះនៅក្នុងគ្រួសាររបស់យើង យើងសុខចិត្តស្លាប់ប្រសើរជាង"។ ដូច្នេះ ខ្ញុំមិនអាចប្រាប់ពួកគាត់ឲ្យដឹងអំពីការពិតរបស់ខ្ញុំបាននោះទេ។ បច្ចុប្បន្ននេះ ខ្ញុំជិតមានការងារល្អមួយហើយ ប៉ុន្តែមកទល់នឹងពេលនេះខ្ញុំនៅមិនទាន់ស្គាល់ពីខ្លួនឯងនិងមិនដឹងច្បាស់អំពីអត្តសញ្ញាណ របស់ខ្លួននៅឡើយ ហើយពេលខ្លះខ្ញុំមានអារម្មណ៍ថាខ្លួនឯងរស់ដូចស្លាប់យ៉ាងដូច្នោះឯង។"*

ការសិក្សាស្រាវជ្រាវមួយនេះផ្តោតសំខាន់ទៅលើអំពើហិង្សា ៤ប្រភេទ(ផ្លូវចិត្ត ផ្លូវកាយ ផ្លូវភេទ និងផ្លូវសេដ្ឋកិច្ច) ចំពោះស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស ដែលបង្កដោយសមាជិកក្រុមគ្រួសារ ដូចអ្វីដែលចិត្រា(នៅចំណុចខាងលើ)និងខេមរា(នៅក្នុងប្រអប់ខាងក្រោម) ធ្លាប់បានជួបប្រទះ ហើយការសិក្សាស្រាវជ្រាវនេះបានធ្វើបទសម្ភាសន៍ជាមួយស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសចំនួន ៦១នាក់ (២៣នាក់ ជាស្ត្រីស្រឡាញ់ស្ត្រី ០៤នាក់ ជាស្ត្រីស្រឡាញ់ទាំងពីរភេទ និង ៣៤នាក់ ជាស្ត្រីប្តូរយេនឌ័រជាបុរស)[1]។ អំពើហិង្សាទាំង៤ប្រភេទនេះ ត្រូវបានចាត់ចូលជា អំពើហិង្សាក្នុងគ្រួសារ យោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការការពារមិនឲ្យមានអំពើហិង្សាក្នុងគ្រួសារនិងការការពារជនរងគ្រោះ(២០០៥)។ ភស្តុតាងជាក់ស្តែងបានបង្ហាញឲ្យឃើញថា ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសជាច្រើននាក់ប្រឈមមុខនឹងការរើសអើងនិងទទួលរងអំពើហិង្សាដោយសារតែគ្មាននិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ(CCHR 2015; ROCK 2015; CCHR2016; CCHR 2017)។ ដោយឡែកការសិក្សាស្រាវជ្រាវមួយនេះ គឺផ្តោតសំខាន់ជាពិសេសលើ ទម្រង់នៃអំពើហិង្សាដែលត្រូវបានមជ្ឈដ្ឋានទូទៅមើលរំលងឬមិនទទួលបានការអើពើពីសង្គមទៅលើស្ថានភាពនៃ**អំពើហិង្សាបង្កឡើងដោយសមាជិកគ្រួសារ**។

[1] សេចក្តីពន្យល់ពីគោលបំណងនៃការសិក្សាស្រាវជ្រាវ វិធីសាស្ត្រ ក្រុមគោលដៅ និងតំបន់គោលដៅ មាននៅក្នុងឯកសារឧបសម្ព័ន្ធ១-៣

**រត់ចេញពីផ្ទះ**

**រឿងរ៉ាវរបស់ ខេមរា អាយុ ២៤ឆ្នាំ ជាស្រ្តីប្លូរយេនឌ័រជាបុរសនិងជាអ្នកចែកបៀអាជីបនៅក្នុងកាស៊ីណូ**

*"នៅពេលដែលខ្ញុំបានប្រាប់ឪពុកម្តាយអំពីអត្តសញ្ញាណយេនឌ័រពិតប្រាកដរបស់ខ្ញុំ ពួកគាត់បានបដិសេធមិនទទួលស្គាល់ភាពពិតជាខ្លួនខ្ញុំទេ ហើយពួកគាត់សម្តែងចេញនូវអាការៈខុសប្រក្រតីមកលើរូបខ្ញុំ។ ស្ថានភាពជីវិតរបស់ខ្ញុំនៅពេលនោះ ពោរពេញទៅដោយទុក្ខសោកនិងវិបត្តិយ៉ាងច្រើន ហើយវាបានធ្វើឲ្យខ្ញុំមានថាអារម្មណ៍កើតទុក្ខស្ទើរតែគ្រប់ពេល។ ខ្ញុំបានក្លាយជាមនុស្សម្នាក់បាក់ទឹកចិត្តនិងកើតទុក្ខជាខ្លាំង ដោយសារឪពុកម្តាយរបស់ខ្ញុំមិនអាចទទួលស្គាល់ការពិតរបស់ខ្ញុំជាខ្ញុំ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយពួកគាត់ជាមនុស្សដែលខ្ញុំទុកចិត្ត ស្រឡាញ់ និងគោរពជាទីបំផុត។ ពេលខ្លះខ្ញុំក៏មិនយល់ដែរថាហេតុអ្វីបានជាពួកគាត់មិនអាចទទួលស្គាល់ខ្ញុំជាខ្ញុំបាន ទាំងដែលពួកគាត់ជាអ្នកដែលនៅក្បែរនិងលើកទឹកចិត្តក្នុងជីវិតរបស់ខ្ញុំតាំងតែពីដើមរហូតមក។ ដូច្នេះហើយ ខ្ញុំក៏សម្រេចចិត្តរត់ចេញពីផ្ទះរបស់ខ្ញុំនៅភ្នំពេញ ហើយផ្លាស់មកនៅកន្លែងថ្មីមួយទៀតជាមួយមិត្តស្រីរបស់ខ្ញុំ។"*

របាយការណ៍នៃការសិក្សាស្រាវជ្រាវនេះមានគោលបំណងឲ្យស្រ្តីស្រលាញ់ស្រ្តី ស្រ្តីស្រលាញ់ទាំងពីរភេទ និងស្រ្តីប្តូរយេនឌ័រជាបុរសអាចចែករំលែកបទពិសោធន៍និងរឿងរ៉ាវលំបាកៗជាច្រើនដែលគេបានជួបប្រទះនៅក្នុងជីវិត ដោយសង្ឃឹមថាអាចធ្វើឲ្យអ្នកអានអាចសិក្សារៀនសូត្រអំពីវិសមភាពនៅក្នុងសង្គម ដែលកម្រចែករំលែកជាសាធារណៈ ហើយអាចឲ្យអ្នកអានធ្វើការឆ្លុះបញ្ចាំងនូវបុព្វសិទ្ធិរបស់ខ្លួនផងដែរ។ ការសិក្សាស្រាវជ្រាវនេះ ក៏មានបំណងធ្វើការរួមចំណែក ជជែកវែកញែក និងកាត់បន្ថយនូវរាល់ទម្រង់នៃការរើសអើងនិងអំពើហិង្សានៅក្នុងសង្គមកម្ពុជាផងដែរ។

*២. អំពើហិង្សាបង្កដោយសមាជិកគ្រួសារ*

"កូនស្រីនៅតែបន្តទទួលរងសម្ពាធ ដើម្បីធ្វើយ៉ាងណាឲ្យពួកគេក្លាយជាក្មេងស្រីល្អ ហើយនឹងក្លាយទៅជាស្ត្រីល្អម្នាក់ក្រោមការថែទាំរបស់ឪពុកម្តាយ។ បើទោះបីជាការរំពឹងទុកទាំងនោះមិនត្រូវបាននិយាយដោយផ្ទាល់ទៅកាន់កូនស្រីក៏ដោយ ក៏ការដាក់សម្ពាធពីឪពុកម្តាយទៅលើកូនស្រីមានសភាពធ្ងន់ធ្ងរដែរ។ ហេតុនេះ ពួកគេនៅតែបន្តមានឧបសគ្គរាំងនៅក្នុងជីវិតនិងបន្តលាក់បាំងអត្តសញ្ញាណរបស់ខ្លួន ក្រោមហេតុផលមួយគឺខ្លាចឪពុកម្តាយមានការពិបាកចិត្តជាពិសេសគឺម្តាយ។ ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស ប្រឈមនឹងភាពងាយរងគ្រោះយ៉ាងខ្លាំង ដោយសារតែ ពួកគេទទួលរងសម្ពាធពីខាងផ្នែកវប្បធម៌និងប្រពៃណី ដែលជាបទដ្ឋានដ៏សែនតឹងរ៉ឹងដែលបានរឹតត្បិតសិទ្ធិសេរីភាពរបស់កូនស្រីនៅក្នុងសង្គមរបស់យើង។"

**បុគ្គលិកភ្នាក់ងារសហប្រជាជាតិ**

**តើស្ថានភាពនៅជុំវិញ ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស មានលក្ខណៈល្អប្រសើរឡើងដែរឬទេ?** អ្នកដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវ ក្រៅពីស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រលាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសភាគច្រើនសុទ្ធតែបានយល់ថាស្ថានភាពស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសមានលក្ខណៈល្អប្រសើរគួរឲ្យកត់សម្គាល់ច្រើននៅប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយការថយចុះនៃការរើសអើងក្នុងទីសាធារណៈធ្វើឲ្យពួកគេក៏ទទួលបានផលប្រយោជន៍ខាងផ្នែកសេរីភាពមួយចំនួនផងដែរ។ មន្ត្រីរាជរដ្ឋាភិបាលកម្ពុជាបានមានប្រសាសន៍ថា *"ការរើសអើងប្រឆាំងនឹងស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស គឺពិតជាមានមែននៅក្នុងប្រទេសកម្ពុជា ហើយពួកយើងជាមន្ត្រីក៏មិនអាចបដិសេធបានដែរ ប៉ុន្តែយើងសង្កេតឃើញថា មានការចងក្រងបណ្តាញ និងវេទិការមួយចំនួនបានរៀបចំដោយអង្គការក៉េ ដែលអាចអនុញ្ញាតឲ្យពួកគេទទួលបានការគាំទ្រគ្នាទៅវិញទៅមកដែលពុំធ្លាប់មានពីមុនមក។"* ផ្អែកតាមរបកគំហើញពីការសិក្សាស្រាវជ្រាវនេះបានឲ្យដឹងថា បើទោះបីជាមានការលើកឡើងបែបនេះក៏ដោយ ក៏ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសខ្លួនឯងពុំបានមើលឃើញដូចអ្វីដែលបានលើកឡើងខាងលើនោះទេ។ ពួកគេយល់ឃើញថា សង្គមនៅតែបន្តការរើសអើងប្រឆាំងស្អប់ ហើយថែមទាំងមិនអនុញ្ញាតឲ្យមានវត្តមានរបស់ពួកគេនៅក្នុងសហគមន៍ថែមទៀត។ អ្វីដែលធ្ងន់ធ្ងរជាងនេះទៅទៀតនោះគឺ ទម្រង់នៃការរើសអើងប្រភេទនេះកើតចេញពីសមាជិកក្រុមគ្រួសាររបស់ពួកគេផ្ទាល់ទៀតផង។ ដូចអ្វីដែលបានលើកឡើងដោយបុគ្គលិកភ្នាក់ងារសហប្រជាជាតិថា *"នៅក្នុងប្រទេសកម្ពុជាការរើសអើងប្រឆាំងនឹងកុមារ ដែលមានអត្តសញ្ញាណយេនឌ័រឬនិន្នាការភេទជាស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស គឺមានប្រភពដំបូងបង្អស់កើតចេញពីសមាជិកគ្រួសារ។"* អំពើហិង្សាក្នុងគ្រួសារត្រូវបានមជ្ឈដ្ឋានទូទៅមើលរំលងពីព្រោះការយកចិត្តទុកដាក់ជាសាធារណៈភាគច្រើនផ្តោតសំខាន់តែទៅលើប្រភេទ នៃអំពើហិង្សាដោយប្រើប្រាស់ពាក្យសម្តីមិនសមរម្យឬហិង្សាលើរូបរាងកាយ តាមរយៈបុរេវិនិច្ឆ័យការសើចចំអក ឬសម្លុតគំរាមទៅកាន់ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសនៅក្នុងសាលា។

***គំនូសបង្ហាញ១៖ បទពិសោធន៍អំពើហិង្សារបស់ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសនៅក្នុងជីវិតរបស់ពួកគេ***




**កម្រិតនៃការកើតឡើងនូវអំពើហិង្សាគ្រួសារចំពោះស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស៖** របកគំហើញដ៏គួរឲ្យភ្ញាក់ផ្អើលតាមរយៈការសិក្សាស្រាវនេះគឺ ៨១% ស្មើនឹង ២៥នាក់នៃស្ត្រី

ស្រឡាញ់ស្រ្តី ស្រ្តីស្រឡាញ់ទាំងពីរភេទ និងស្រ្តីប្តូរយេនឌ័រជាបុរស ដែលមានអាយុតិចជាង ៣៥ឆ្នាំ ធ្លាប់មានពិសោធន៍ទទួលរងអំពើហិង្សាដែលបង្កដោយសមាជិកគ្រួសារ ហើយភាគច្រើនគឺបានកើតឡើងនៅពេលពួកគេនៅវ័យក្មេងនៅឡើយ។ នៅក្នុងន័យនេះ ផ្ទះសម្រាប់ក្រុមស្រ្តីស្រឡាញ់ស្រ្តី ស្រ្តីស្រឡាញ់ទាំងពីរភេទ និងស្រ្តីប្តូរយេនឌ័រជាបុរសមិនមែនជាកន្លែងដែលមានសុវត្ថិភាពនោះទេ។ ហេតុនេះហើយ ស្រ្តីស្រឡាញ់ស្រ្តី ស្រ្តីស្រឡាញ់ទាំងពីរភេទ និងស្រ្តីប្តូរយេនឌ័រជាបុរសជាច្រើន ត្រូវបង្ខំចិត្តចាកចេញពីផ្ទះនៅពេលដែលពួកគេមិនអាចស៊ូទ្រាំនឹងការឈឺចាប់ជាមួយនឹងក្រុមគ្រួសាររបស់ខ្លួនបានតទៅទៀត ឬករណីមួយចំនួនទៀត គឺពួកគេត្រូវបានឪពុកម្តាយបណ្តេញចេញពីផ្ទះតែម្តង។

*២.១. អំពើហិង្សាក្នុងគ្រួសារ គឺជាទម្រង់អំពើហិង្សាដ៏ឃោរឃៅបំផុតសម្រាប់ស្រ្តីស្រឡាញ់ស្រ្តី ស្រ្តីស្រឡាញ់ទាំងពីរភេទ និងស្រ្តីប្តូរយេនឌ័រជាបុរស*

ទម្រង់នៃការរើសអើងនិងអំពើហិង្សាដែលពួកគេបានធ្លាប់បានជួបប្រទះ គឺពិតជាមានលក្ខណៈខុសៗពីគ្នាទៅតាមដំណាក់កាលនៃឆាកជីវិតរបស់ពួកគេម្នាក់ៗ ដូចជានៅកន្លែងធ្វើការ នៅក្នុងសហគមន៍ ឬក៏ម្យ៉ាងទៀតនៅតាមទីសាធារណៈ ដូចជានៅទីសួនច្បារសាធារណៈ និងនៅតាមទីផ្សារជាដើម។ ទោះបីជាយ៉ាងនេះក៏ដោយ ការសិក្សាស្រាវជ្រាវបានសម្គាល់ថា ការរើសអើងនិងអំពើហិង្សាដែលស្តែងចេញតាមរយៈមជ្ឈដ្ឋានខាងក្រៅពុំមែនជាសមាជិកក្នុងគ្រួសារ គឺពុំសូវមានឥទ្ធិពលធ្ងន់ធ្ងរដូចជាអំពើហិង្សាដែលបង្កដោយសមាជិកគ្រួសារនោះទេ។ អំពើហិង្សាក្នុងគ្រួសារ គឺជាបទពិសោធន៍ដែលមិនអាចបំភ្លេចបាននិងឈឺចាប់បំផុតសម្រាប់ស្រ្តីស្រឡាញ់ស្រ្តី ស្រ្តីស្រឡាញ់ទាំងពីរភេទ និងស្រ្តីប្តូរយេនឌ័រជាបុរស ដោយសារតែអំពើហិង្សាប្រភេទនេះបង្ខំឲ្យមានការចាកចេញពីផ្ទះ បង្ខំឲ្យបិទបាំងអត្តសញ្ញាណពិត ហើយអាចបង្កឲ្យមានបញ្ហាផ្លូវចិត្តទៀតផង។

**ឡូន អាយុ ២៩ឆ្នាំ ជាស្រ្តីប្តូរយេនឌ័រជាបុរស** បានចាកចេញពីគ្រួសារ ដោយសារតែភាពភ័យខ្លាចនៃការបដិសេធមិនទទួលស្គាល់ពីគ្រួសាររបស់គាត់ ហើយគាត់បានមាននិយាយថា *"ខ្ញុំសុខចិត្តចាកចេញពីផ្ទះ ព្រោះខ្ញុំមិនចង់ឲ្យឪពុកម្តាយរបស់ខ្ញុំដឹងអំពីអត្តសញ្ញាណយេនឌ័ររបស់ខ្ញុំ។"* **រដ្ឋា អាយុ៣២ឆ្នាំជាស្រ្តីប្តូរយេនឌ័រជាបុរស** និងជាបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលបានលើកឡើងថា *"នៅពេលដែលខ្ញុំឈឺចាប់ ដោយសារតែការបាត់បង់ស្នេហា ខ្ញុំគិតថាខ្ញុំអាចធ្វើចិត្តបាន ក៏ប៉ុន្តែពាក្យសម្តីដ៏មុតស្រួចរបស់ម្តាយរបស់ខ្ញុំ គឺវាពិតជាធ្វើឲ្យខ្ញុំឈឺចាប់ខ្លាំងណាស់ ពីព្រោះខ្ញុំមានម្តាយតែម្នាក់គត់ប៉ុណ្ណោះ"*។ **សារ៉ាត់ មានអាយុ៣៧ឆ្នាំ ជាស្រ្តីស្រឡាញ់ស្រ្តី** ហើយធ្លាប់បានទទួលរងការគាបសង្កត់ពីឪពុកម្តាយដែលចង់ "**កែប្រែ**" និន្នាការភេទរបស់នាង ជាពិសេសម្តាយរបស់នាងបានមានប្រសាសន៍ថា *"ពេលខ្លះអ្នកជិតខាងនិយាយដើមខ្ញុំនិងរើសអើងខ្ញុំ ហើយសូម្បីតែអ្នកធ្វើការជាមួយគ្នាក៏ធ្វើបែបនេះដាក់ខ្ញុំដែរ។ ទោះជាយ៉ាងណាក៏ដោយ ការដែលឪពុកម្តាយរបស់ខ្ញុំបដិសេធមិនទទួលស្គាល់ខ្ញុំ ខ្ញុំនៅតែគិតថាគឺជាភាពឈឺចាប់ខ្លាំងបំផុតសម្រាប់ខ្ញុំ។ វាជារឿងមួយដែលធ្វើឲ្យខ្ញុំឈឺចាប់ជាខ្លាំង ដោយសារតែពួកគាត់ជាមនុស្សដែលខ្ញុំស្រឡាញ់និងគោរពបំផុត។"*

**រៀបការដើម្បីឲ្យម្ដាយសប្បាយចិត្ត**

**រឿងរ៉ាវរបស់ ទីម អាយុ ៦៨ឆ្នាំ ស្ត្រីប្ដូរយេនឌ័រជាបុរស**

**ទីម** ចាប់ផ្ដើមកត់សម្គាល់អត្តសញ្ញាណយេនឌ័ររបស់ខ្លួនឯង នៅពេលដែលគាត់រៀននៅកម្រិតបឋម សិក្សា *"ពីមុនខ្ញុំចូលចិត្តលេងល្បែងដែលក្មេងប្រុសចូលចិត្តលេង ហើយខ្ញុំក៏បានចូលរួមលេងជាមួយ ក្មេងប្រុសៗឯទៀតដែរ។ ពេលនោះខ្ញុំចូលចិត្តកាត់សក់ខ្លី។"* ប៉ុន្តែក្រោយពេលដែលគាត់ធំដឹងក្ដី ជា មនុស្សស្រី ហើយក៏បានរៀបការជាមួយនឹងបុរសទៅតាមការរៀបចំទុកដាក់របស់ម្ដាយគាត់។ *"ខ្ញុំបាន លាក់បាំងអត្តសញ្ញាណយេនឌ័ររបស់ខ្ញុំ ហើយរៀបការជាមួយនឹងប្ដីរបស់ខ្ញុំព្រមទាំងមានកូនជាមួយគ្នាផងដែរ។ ប៉ុន្តែកូនៗទាំងអស់របស់ខ្ញុំបានស្លាប់នៅក្នុងសម័យខ្មែរក្រហម"*។ គាត់បានបន្តលាក់អត្តសញ្ញាណយេនឌ័ររបស់គាត់អស់ជាង ២៥ឆ្នាំ ហើយគាត់ក៏សម្រេចចិត្តបង្ហាញអត្តសញ្ញាណយេនឌ័រ ចេញមកក្រៅ ដោយសារតែប្ដីនិងឪពុករបស់គាត់បានលាចាកលោកទៅហើយ។ ការស្លាប់របស់អ្នក ទាំងពីរបានអនុញ្ញាតឲ្យគាត់អាចបង្ហាញនូវអត្តសញ្ញាណយេនឌ័ររបស់គាត់ ពីព្រោះគាត់គិតថាយ៉ាងហោចណាស់គាត់ក៏មិនបានធ្វើឲ្យឪពុករបស់គាត់ពិបាកដោយសារតែគាត់ដែរ (ដោយសារតែអត្តសញ្ញាណរបស់គាត់)។ ប៉ុន្តែអត្តសញ្ញាណយេនឌ័ររបស់គាត់បានបង្កភាពភ្ញាក់ផ្អើលដល់សមាជិកក្នុងគ្រួសារ។ គាត់ត្រូវបានសមាជិកគ្រួសារនិងសាច់ញាតិ ដែលរស់នៅក្នុងស្រុកជាមួយគ្នាចំអកមើលងាយនិងរើសអើង។ គាត់បាននិយាយថា *"សមាជិកគ្រួសាររបស់ខ្ញុំ ជារឿយៗហៅខ្ញុំថា មីខ្ទើយ ហើយវាធ្វើឲ្យខ្ញុំឈឺចាប់យ៉ាងខ្លាំង ព្រោះខ្ញុំមិនអាចផ្លាស់ប្ដូរអត្តសញ្ញាណរបស់ខ្ញុំបានទេ។"*

### *២.២. អំពើហិង្សាលើផ្លូវចិត្តបង្កដោយសមាជិកគ្រួសារ*

ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ ស្ត្រីប្ដូរយេនឌ័រជាបុរសច្រើនជាងពាក់កណ្ដាល ដែលបានចូលរួមនៅក្នុងការសិក្សាស្រាវជ្រាវនេះ (៥៦% នៃ៣៤នាក់) បានរាយការណ៍ថា ពួកគេទទួលបានបទសោធន៍អំពើហិង្សាលើផ្លូវចិត្តបង្កឡើងដោយសមាជិកគ្រួសារ ដោយសារកត្តានិន្នាការភេទ ឬ អត្តសញ្ញាណយេនឌ័រ។ ដូច្នេះហើយ គួរធ្វើការកត់សម្គាល់ដែរថា គ្រប់ប្រភេទនិងទម្រង់នៃអំពើហិង្សាទាំងអស់ តែងតែមានវត្តមាននៃអំពើហិង្សាលើផ្លូវចិត្តអមមកជាមួយ។ អ្វីដែលគួរឲ្យភ្ញាក់ផ្អើល គឺទម្រង់នៃអំពើហិង្សាលើផ្លូវចិត្តបាន កើតឡើងយ៉ាងខ្លាំងទៅលើស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្ដូរយេនឌ័រជាបុរសដែលមានអាយុក្រោម

៣៥ឆ្នាំ ស្មើនឹង៨១% (២៥នាក់) បានរាយការណ៍ថាធ្លាប់ មានបទពិសោធន៍ជាមួយអំពើហិង្សាលើផ្លូវចិត្ត ដោយសារកត្តានិន្នាការភេទ ឬ អត្តសញ្ញាណយេនឌ័រ។

> *"ការយល់ឃើញរបស់ខ្ញុំផ្ទាល់គឺថាក្រុមគ្រួសារភាគច្រើនមិនទទួលស្គាល់កូនរបស់ខ្លួននោះទេ ប្រសិនបើកូនជា ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស"*។
>
> **ដកស្រង់ពីអាជ្ញាធរមូលដ្ឋាន**

**សេចក្តីភ័យខ្លាចចំពោះការបដិសេធ ឬ ការមិនទទួលស្គាល់ពីសំណាក់ឪពុកម្តាយ៖** ជាទូទៅ ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសព្យាយាមលាក់ទុកអត្តសញ្ញាណយេនឌ័ររបស់ខ្លួន ដោយប្រើពេលជាច្រើនឆ្នាំ ដោយសារតែខ្លាចការបដិសេធមិនទទួលយកពីសមាជិកក្នុងគ្រួសារ ជាពិសេសគឺឪពុកម្តាយ។ **សុខលាង អាយុ ២៣ឆ្នាំ** មកដល់ពេលនេះ គាត់នៅតែរក្សាការសម្ងាត់អំពីអត្តសញ្ញាណយេនឌ័រ របស់គាត់ដដែល ដោយគាត់បានលើកឡើងថា *"នៅពេលដែលខ្ញុំឮម្តាយរបស់ខ្ញុំរិះគន់ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសទាំងអស់ថាជាមនុស្ស "អាក្រក់" វាធ្វើឲ្យខ្ញុំឈឺចាប់ខ្លាំងណាស់ ហើយវាធ្វើឲ្យខ្ញុំយល់ថា ឪពុកម្តាយរបស់ខ្ញុំមិនអាចទទួលស្គាល់ការពិតរបស់ខ្ញុំបានទេ (ក្នុងនាមខ្ញុំជាអ្នកស្រឡាញ់ទាំងពីរភេទ)"*។ បទដ្ឋានសង្គមប្រព័ន្ធយេនឌ័រតឹងរ៉ឹង(ប្រុសនិងស្រី) នៅក្នុងសង្គមកម្ពុជា គឺជាកត្តាដ៏ធំមួយដែលគាបសង្កត់ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស។ នៅពេលដែលពួកគេធ្វើការសម្រេចចិត្តប្រាប់ឪពុកម្តាយនូវការពិតអំពីអត្តសញ្ញាណផ្លូវភេទរបស់ខ្លួន ពួកគេអាចត្រូវបានបដិសេធថា វារឿងដែលមិនពិត។

**ការមិនរាប់រកពីសមាជិកគ្រួសារ៖** ស្ត្រីប្តូរយេនឌ័រជាបុរសមួយចំនួន បានរាយការណ៍ថាសមាជិកគ្រួសាររបស់ពួកគេចាប់ផ្តើមមិនរាប់រកពួកគេនៅក្នុងផ្ទះ។ ឧទាហរណ៍៖ **សុខា អាយុ ២៤ឆ្នាំ ជាស្ត្រីប្តូរយេនឌ័រជាបុរស** បាននិយាយថា *"ខ្ញុំមានអារម្មណ៍ឈឺចាប់បំផុតនៅពេលដែលឪពុកម្តាយរបស់ខ្ញុំមិនព្រមស្តាប់ខ្ញុំបកស្រាយទាល់តែសោះ នៅពេលដែលខ្ញុំចង់និយាយជាមួយពួកគាត់។"* **វតនា អាយុ ២៦ឆ្នាំ ជាស្ត្រីប្តូរយេនឌ័រជាបុរសនិងជាគ្រូបង្រៀននៅសាលាឯកជនមួយ**បាននិយាយថា *"មកទល់ពេលនេះ ខ្ញុំត្រូវបានគ្រួសាររើសអើងនិងហាមមិនឲ្យប្រាប់គេថា ខ្ញុំជាកូនរបស់គាត់ទេរាល់ពេលដែលខ្ញុំនិងគ្រួសារទៅខាងក្រៅជុំគ្នា ប្រសិនបើមានគេសួរថា "ខ្ញុំជានរណា?" គាត់តែងតែប្រាប់គេថា ខ្ញុំជាក្មួយ ឬ ជាអ្នករស់នៅជាមួយគ្នា និង មិនមានជាប់សាច់ឈាមក្នុងគ្រួសារនោះទេ។ ដូចគ្នាដែរ បងស្រីបង្កើតដែលរស់នៅជាមួយខ្ញុំ សព្វថ្ងៃក៏មិនដែលប្រាប់គេថាខ្ញុំជាប្អូនបង្កើតរបស់គាត់ដែរ។"* ការដែលបដិសេធថា "ពុំមានជាប់សាច់ឈាមនៅក្នុងគ្រួសារ" ជាបញ្ហាដែលនាំឲ្យមានការបំផ្លាញនូវសេចក្តីថ្លៃថ្នូររបស់បុគ្គលដែលជា ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស ហើយវាពិតជាឈឺចាប់សម្រាប់ពួកគាត់ ដែលគួរតែអាចជ្រកកោននៅក្នុងផ្ទះដោយសុវត្ថិភាពបាន ។

**បង្ខំឲ្យបែកគ្នាជាមួយដៃគូ៖** ករណីឪពុកម្តាយបានបង្ខំកូន ឲ្យបែកគ្នាជាមួយដៃគូ គឺជារឿងដែលបានកើតមានឡើងជាញឹកញាប់ណាស់ នៅក្នុងការសិក្សាមួយនេះ។ **គីម អាយុ៥០ឆ្នាំ ជាស្ត្រីស្រឡាញ់ស្ត្រី** បាននិយាយថា *"ម្តាយរបស់ខ្ញុំបានព្យាយាមតាមបំបែកខ្ញុំចេញពីដៃគូរបស់ខ្ញុំជាច្រើនលើក ហើយក៏បានបង្ខំឲ្យខ្ញុំ រៀប*

*ការជាមួយនឹងបុរសផងដែរ។*” គីម មិនបានយល់ព្រមជាមួយនឹងម្ដាយនោះទេ ហើយនាងបានសម្រេច ចិត្តចាកចេញពីផ្ទះរបស់នាង និងចាប់ផ្ដើមរស់នៅជាមួយនឹងដៃគូរបស់នាង។ ឪពុកម្ដាយរបស់ ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្ដូរយេនឌ័រជាបុរស ដែលចូលរួមនៅក្នុងការសិក្សាស្រាវជ្រាវ នេះបានរាយការណ៍ថា ពួកគាត់ពេលខ្លះបានព្យាយាមបំបែកកូនពីដៃគូកូនរបស់ខ្លួនចេញ។

**យកទៅដាក់នៅក្នុងមណ្ឌលកែប្រែ**

**រឿងរ៉ាវរបស់ សាម (អាយុ ២៧ឆ្នាំ ជាស្ត្រីប្ដូរយេនឌ័រជាបុរស)**

**សាម** បានកើតនៅក្នុងខេត្តសៀមរាប មានបងប្អូន ០៧នាក់ មានម្ដាយជាវេជ្ជបណ្ឌិតវេជ្ជសាស្ត្រ ហើយឪពុករបស់គាត់ជាមេភូមិ។ គាត់ចាប់ផ្ដើមសម្គាល់អត្តសញ្ញាណយេនឌ័ររបស់ខ្លួនឯងតាំងពីថ្នាក់ទី៦ ហើយម្ដាយរបស់គាត់មិនដែលទទួលស្គាល់គាត់នោះទេ និង~~ហើយរបស់គាត់~~ព្យាយាម “កែប្រែ” អត្តសញ្ញាណយេនឌ័ររបស់សាមរហូត។ សាមបាននិយាយថា *“ម្ដាយរបស់ខ្ញុំតែងនិយាយពាក្យសម្ដីមិនគប្បីដាក់ខ្ញុំ ដូចគាត់ធ្លាប់បាននិយាយថា “ប្រសិនបើអញដឹងថា អញមានកូនបែបនេះ(ស្ត្រីប្ដូរយេនឌ័រជាបុរស) អញនឹងសម្លាប់ឯងតាំងពីនៅតូចបាត់ទៅហើយ។”* ក្រៅពីទទួលរងសម្ពាធនិងការលំបាកផ្សេងៗ សាម ប្រឹងប្រែងរៀនសូត្រនិងបានចុះឈ្មោះចូលរៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ សាមត្រូវបានម្ដាយបង្ខំឲ្យត្រលប់ទៅខេត្តកំណើតវិញ នៅពេលដែលរៀនបានឆ្នាំទី២ ដោយសារតែម្ដាយបានដឹងថា សាមមានទំនាក់ទំនងស្នេហាជាមួយមនុស្សស្រី។ សាមបាននិយាយបន្តទៀតថា *“នៅពេលនោះខ្ញុំបានព្យាយាមពន្យល់ម្ដាយរបស់ខ្ញុំអំពីអត្តសញ្ញាណយេនឌ័រពិតប្រាកដរបស់ខ្ញុំ ប៉ុន្តែវាគ្មានប្រយោជន៍នោះទេ។ បន្ទាប់មកម្ដាយរបស់ខ្ញុំបានយកខ្ញុំទៅដាក់នៅក្នុងមណ្ឌលកែប្រែក្នុងគោលបំណងចង់ “កែប្រែ” អត្តសញ្ញាណយេនឌ័ររបស់ខ្ញុំ។”* ប៉ុន្តែសាមបានរត់គេចខ្លួនក្រោយពីរស់~~នៅអស់~~នៅក្នុងមណ្ឌលកែប្រែអស់រយៈពេល ០៣ខែ~~។ សាម ក៏បានសម្រេចចិត្តចាកចេញពីម្ដាយរបស់គាត់~~ ហើយមករស់នៅភ្នំពេញជាមួយមិត្តស្រី~~ម្ដងទៀត~~។

## ២.៣. *អំពើហិង្សាលើផ្លូវកាយបង្កដោយសមាជិកគ្រួសារ*

ការសិក្សាស្រាវជ្រាវនេះ បានធ្វើការចងក្រងបញ្ហារបស់ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្ដូរយេនឌ័រជាបុរសចំនួន ០៤នាក់ (១១%) ដែលមានបទពិសោធន៍ទទួលរងអំពើហិង្សាលើផ្លូវកាយ។ អំពើហិង្សាដែលឪពុកម្ដាយបានបង្ខំ ឬ ទាត់ធាក់កូនរបស់ខ្លួនដែលជាស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្ដូរយេនឌ័រជាបុរស ដោយចាប់ចាក់សោឃុំទុកនៅក្នុងបន្ទប់ កម្រនឹងទទួលបានការរាយការណ៍ណាស់។ គ្មាននរណាម្នាក់ចង់និយាយអំពីបញ្ហានេះជាសាធារណៈនោះទេពីព្រោះសមាជិកគ្រួសារគិតថាវាជា“ការអាម៉ាស់របស់គ្រួសារ” ដែលត្រូវតែលាក់ទុក។ ដូច្នេះហើយសាមីខ្លួនដែលមានអត្តសញ្ញាណយេនឌ័រ ឬនិន្នាការភេទជាស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្ដូរយេនឌ័រជាបុរស មិនហ៊ានបញ្ចេញនូវអត្តសញ្ញាណយេន

ឌ័ររបស់ខ្លួននិងអំពើហិង្សាដែលខ្លួនបានជួបប្រទះឡើយ ដោយសារតែខ្លាចថា វានឹងក្លាយទៅជាមូលហេតុដែលនាំឲ្យមានអំពើហិង្សាបន្ថែមទៀតមកលើខ្លួន។

**វាយដំដោយសមាជិកគ្រួសារ៖** ជាទូទៅ អ្នកដែលបង្កអំពើហិង្សា គឺឪពុកវាយកូនស្រី ប៉ុន្តែករណីខ្លះបងប្រុស ក៏ជាអ្នកប្រើហិង្សាផងដែរ។ **គៀត អាយុ ៣៧ឆ្នាំ ជាស្ត្រីប្តូរយេនឌ័រជាបុរស** កំពុងធ្វើការនៅក្នុង រោងចក្រកាត់ដេរបាននិយាយថា *"បងប្រុសរបស់ខ្ញុំស្អប់ខ្ញុំ ហើយបានវាយខ្ញុំយ៉ាងខ្លាំង"* ហើយ ០៣នាក់ ផ្សេងទៀតធ្លាប់មានបទពិសោធន៍រងអំពើហិង្សាលើផ្លូវកាយ បានលើកឡើងថា ពួកគេបានទទួលរងនូវអំពើហិង្សា ធ្ងន់ធ្ងរតាមរយៈការវាយដំយ៉ាងខ្លាំងពីសមាជិកគ្រួសារ។ ទោះបីជាទំហំនៃការស្រាវជ្រាវតូចក៏ដោយ ភស្តុតាង ដែលបញ្ជាក់ថាស្ត្រីប្តូរយេនឌ័រជាបុរសរងនូវអំពើហិង្សាលើផ្លូវកាយមានកម្រិតខ្ពស់ រាប់បញ្ចូលទាំងវាយដំ(បទពិសោធន៍ទាំងនោះ រួមទាំងការឈឺចាប់ផ្នែកផ្លូវចិត្តផងដែរ)។ ស្ត្រីប្តូរយេនឌ័រជាបុរសភាគច្រើន ព្យាយាមបញ្ចេញនូវភាពជាបុរសរបស់ខ្លួន តាមរយៈរូបរាងខាងក្រៅ ហើយឪពុកម្តាយ(ជាពិសេសឪពុក)មិនសប្បាយចិត្តជាមួយនឹងលក្ខណៈសម្បត្តិរបស់កូនស្រីរបស់ពួកគាត់នោះទេ។

**បង្ខំឲ្យនៅតែក្នុងផ្ទះ ឬបណ្តេញចេញពីគ្រួសារ៖** មានស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសជាច្រើនបានរាយការណ៍ថា ពួកគេត្រូវបានហាមឃាត់មិនឲ្យចេញទៅខាងក្រៅផ្ទះហើយឲ្យនៅតែក្នុងបន្ទប់ ដើម្បីកុំឲ្យពួកគេបានជួបជាមួយនឹងមិត្តភក្តិ។ **ពេជ្រ អាយុ ២០ឆ្នាំ ជាស្ត្រីស្រឡាញ់ស្ត្រីនិងជានិស្សិត** បាននិយាយថា *"នៅពេលដែលខ្ញុំចង់ចេញទៅក្រៅជាមួយនឹងមិត្តស្រីរបស់ខ្ញុំ ម្តាយរបស់ខ្ញុំតែងតែប្រើហិង្សា ដើម្បីកុំឲ្យខ្ញុំអាចចេញទៅក្រៅជាមួយមិត្តស្រីរបស់ខ្ញុំ។ ម្តាយរបស់ខ្ញុំឃុំខ្ញុំនៅក្នុងផ្ទះនិងបិទសិទ្ធិរបស់ខ្ញុំមិនឲ្យចេញក្រៅជាមួយមិត្តភក្តិ។"*

**ត្រូវបានម្តាយបណ្តេញចេញពីផ្ទះ**

**ម៉ាណែត ២៩ឆ្នាំ ជាស្ត្រីប្តូរយេនឌ័រជាបុរស នៅភ្នំពេញ**

**ម៉ាណែត** ធំដឹងក្តីនៅទីក្រុងភ្នំពេញ ហើយជាបុគ្គលិកនៃអង្គការមិនមែនរដ្ឋាភិបាលមួយក្រោយពេល ដែលគាត់បានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ។ គាត់បានកត់សម្គាល់អត្តសញ្ញាណយេនឌ័ររបស់គាត់នៅពេលគាត់អាយុប្រហែល០៨ឆ្នាំ។ ប៉ុន្តែ គាត់លាក់ទុកអត្តសញ្ញាណនោះ ពីសមាជិកគ្រួសាររបស់គាត់ទាល់តែដល់អាយុ២០ឆ្នាំ។ ថ្ងៃមួយគាត់សម្រេចចិត្តកាត់សក់ខ្លី ដើម្បីបង្ហាញពីអត្តសញ្ញាណយេនឌ័ររបស់គាត់។ "បទពិសោធន៍ដ៏ឈឺចាប់បំផុតរបស់ខ្ញុំ គឺនៅពេលដែលខ្ញុំបើកបង្ហាញ អត្តសញ្ញាណយេនឌ័ររបស់ខ្ញុំទៅកាន់ម្តាយរបស់ខ្ញុំ ហើយគាត់បានប្រតិកម្មយ៉ាងអាក្រក់មកវិញ។ ម្តាយរបស់ខ្ញុំខឹងយ៉ាងខ្លាំង ហើយផ្តល់ជំរើសពីរឲ្យខ្ញុំទីមួយគឺស្តាប់គាត់ធ្វើជា "កូនល្អ"ឬ ទីពីរ យក "ការពិតជាខ្ញុំ"។ វាធ្វើ ឲ្យខ្ញុំពិបាកចិត្តយ៉ាងខ្លាំង ដែលឲ្យខ្ញុំជ្រើសរើសយកជម្រើសតែមួយ ប៉ុន្តែខ្ញុំនិយាយទៅកាន់គាត់ទាំងទឹក ភ្នែកថា៖ "ខ្ញុំជ្រើសយកជម្រើសទីពីរ គឺយក "ការពិតជាខ្ញុំ"។ ក្រោយពីគាត់លឺបែបនេះ គាត់និយាយថា៖ "ចេញពីផ្ទះភ្លាម ហើយដោះគ្រឿងអលង្ការទាំងអស់ទុកនៅហ្នឹងហើយ!" ដោយគ្មានជម្រើស ខ្ញុំត្រូវតែធ្វើតាមគាត់។ វាគឺជាបទពិសោធន៍ដែលឈឺចាប់បំផុតក្នុងជីវិតខ្ញុំ។"

ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស ជាច្រើនដោយមិនគិតវ័យត្រូវទទួលរងសម្ពាធនៃអំពើហិង្សា ដើម្បីធ្វើឲ្យពួកគេ "ក្លាយទៅជាធម្មតាវិញ" ដោយអនុលោមទៅតាមផ្នត់គំនិតយេនឌ័រ ដែលមានឥទ្ធិពលក្នុងសង្គមកម្ពុជា។ នៅពេលស៊ូទ្រាំមិនបានពួកគេក៏សម្រេចចិត្តចាកចេញពីផ្ទះហើយរស់នៅដោយឯករាជ។

## *២.៤. អំពើហិង្សាលើផ្លូវភេទ*

អាពាហ៍ពិពាហ៍រៀបចំទុកដាក់ដោយឪពុកម្តាយ គឺនៅតែបន្តអនុវត្តនៅក្នុងសង្គមកម្ពុជា ហើយនៅក្រោមឥទ្ធិពលនៃបរិបទវប្បធម៌។ ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសជាច្រើននាក់ត្រូវបានបង្ខំឲ្យរៀបការផ្ទុយពីឆន្ទៈរបស់ពួកគេ។ អ្នកខ្លះត្រូវបានឪពុកម្តាយបង្ខំ ហើយអ្នកខ្លះទៀតសុខចិត្តរៀបការទៅតាមការសម្រេចចិត្តរបស់ឪពុកម្តាយ "ដើម្បីធ្វើជាកូនល្អ" និង "ភាពសប្បាយរីករាយរបស់ឪពុកម្តាយ" របស់ខ្លួន។

**បង្ខំឲ្យរៀបការជាមួយបុរស**

**រឿងរ៉ាវរបស់ រូអាត អាយុ ៣៤ឆ្នាំ ស្ត្រីប្តូរយេនឌ័រជាបុរសនិងជាបុគ្គលិកក្រុមហ៊ុនឆ្នោត**

នៅពេលដែលគាត់រៀននៅកម្រិតអនុវិទ្យាល័យ រូអាតដឹងខ្លួនថា ចូលចិត្តស្លៀកពាក់បែបមនុស្សប្រុស ហើយគាត់ក៏បានដឹងថាមនុស្សនៅជុំវិញខ្លួនគាត់និយាយដើមក្នុងន័យរើសអើងគាត់។ ដូច្នេះហើយ *"ខ្ញុំមិនហ៊ានបង្ហាញអត្តសញ្ញាណយេនឌ័ររបស់ខ្ញុំទេ ពីព្រោះមនុស្សគ្រប់គ្នានឹងនិយាយអាក្រក់ពីខ្ញុំ ហើយម្តាយរបស់ខ្ញុំនឹងមិនពេញចិត្ត ដោយសារតែគាត់មិនចូលចិត្តស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ ស្ត្រីប្តូរយេនឌ័រជាបុរស។"* ដើម្បីបំពេញចិត្តម្តាយរបស់គាត់ គាត់បានយល់ព្រមរៀបការជាមួយនឹងបុរស ដែលម្តាយគាត់ជាអ្នកជ្រើសរើសឲ្យ។ គាត់ហៅពេលវេលានោះថា ជារឿងដ៏សែនឈឺចាប់បំផុតដោយបាននិយាយថា *"ខ្ញុំរៀបការជាមួយនឹងបុរសម្នាក់តាមការសម្រេចចិត្តរបស់ម្តាយខ្ញុំ ប៉ុន្តែវាមិនបានផ្លាស់ប្តូរភាពពិតរបស់ខ្ញុំនោះទេ ពីព្រោះអ្វីដែលខ្ញុំធ្វើគឺដើម្បីឲ្យម្តាយរបស់ខ្ញុំសប្បាយចិត្តតែប៉ុណ្ណោះ។ រយៈពេល ៣ឆ្នាំក្រោយពេលរៀបការ វាបានធ្វើឲ្យខ្ញុំមានអារម្មណ៍ឈឺចាប់យ៉ាងខ្លាំង ដោយសារតែខ្ញុំត្រូវលាក់ទុកនូវអត្តសញ្ញាណផ្លូវភេទរបស់ខ្ញុំ។"* ចុងក្រោយ គាត់បានលែងលះពីប្តី របស់គាត់ ហើយបានទៅរស់នៅកន្លែងថ្មីមួយទៀត ក្នុងនាមជាស្ត្រីប្តូរយេនឌ័រជាបុរស គាត់បាននិយាយថា *"ខ្ញុំស្រឡាញ់ខ្លួនខ្ញុំជាខ្ញុំ ហើយឥឡូវនេះខ្ញុំអាចរស់នៅជាខ្ញុំបានហើយ។"*

**រៀបការដោយបង្ខំ៖** ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសចំនួន០៦នាក់ទទួលរងនូវ សម្ពាធឲ្យរៀបការជាមួយបុគ្គលភេទផ្ទុយគ្នា(អ្នកចូលរួមចំនួន២នាក់ធ្លាប់បានរៀបការរួចហើយ)ដើម្បីបញ្ចប់ទំនាក់ទំនងស្នេហាភេទដូចគ្នារបស់ពួកគេ។ មានរបាយការណ៍មួយ ចេញផ្សាយដោយសកម្មជនLGBT បានឲ្យដឹងថា មានស្ត្រីប្តូរយេនឌ័រទៅជាបុរសម្នាក់ត្រូវបានបង្ខំឲ្យរៀបការ ហើយមានផ្ទៃពោះ

ហើយក្រោយមកទៀតគាត់ក៏បានសម្រេចចិត្តយកកូននោះចេញ។ **សានី អាយុ៣៨ឆ្នាំ ជាស្ត្រីប្តូរយេនឌ័រជាបុរស និងជាអ្នករត់ម៉ូតូឌុប**បាននិយាយថា *"ខ្ញុំរៀបការតាមការចង់បានរបស់ឪពុកម្តាយខ្ញុំ និងដើម្បីភាពរីករាយរបស់គាត់។"* បច្ចុប្បន្ននេះ គាត់កំពុងរស់នៅជាមួយនឹងប្រពន្ធនិងកូនរបស់គាត់ដែលមានជាមួយនឹងអតីតប្តីរបស់គាត់។ ស្រដៀងគ្នានេះ **ម៉ី អាយុ៣៥ឆ្នាំ ជាស្ត្រីប្តូរយេនឌ័រជាបុរស ហើយក៏ជាស្ត្រីមេម៉ាយចិញ្ចឹមកូន០៣នាក់**។ គាត់បាននិយាយថា គាត់មានអារម្មណ៍ទទួលបានសេរីភាពជាងមុន ក្រោយពេលលែងលះជាមួយប្តីដែល "គ្មានទំនួលខុសត្រូវ"។ ឥឡូវនេះ គាត់កំពុងតែរស់នៅពោរពេញដោយភាពសប្បាយរីករាយជាមួយនឹងដៃគូជាមនុស្សស្រីដែលគាត់ស្រឡាញ់។"

### *២.៥. អំពើហិង្សាផ្នែកសេដ្ឋកិច្ច*

អំពើហិង្សាផ្នែកសេដ្ឋកិច្ច រាប់បញ្ចូលទាំងការបំផ្លាញទ្រព្យសម្បត្តិរបស់ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ ស្ត្រីប្តូរយេនឌ័រជាបុរស ឬការហាមឃាត់ពួកគេមិនឲ្យទៅរៀន ដោយសារតែឪពុកម្តាយមានអំណាចខាងផ្នែកសេដ្ឋកិច្ចទៅលើកូនរបស់គាត់។ នៅក្នុងការសិក្សាស្រាវជ្រាវនេះមាន ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ ស្ត្រីប្តូរយេនឌ័រជាបុរសមួយចំនួនប៉ុណ្ណោះ ដែលបានរាយការណ៍អំពីបទពិសោធន៍របស់ពួកគេទាក់ទងនឹងអំពើហិង្សា ហើយការឈានចូលទៅដល់បញ្ហាផ្លូវចិត្ត គឺជារឿយៗកើតមានលើស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ ស្ត្រីប្តូរយេនឌ័រជាបុរស រៀងរាល់ពេលដែលពួកគេរងគ្រោះ ឬ ទទួលរងនូវទម្រង់នៃអំពើហិង្សាបីប្រភេទផ្សេងទៀត។

**ហាមឃាត់មិនឲ្យទិញសំលៀកបំពាក់ដែលខ្លួនស្រឡាញ់ ឬ ដកហូតទូរស័ព្ទដៃ៖** មានស្ត្រីប្តូរយេនឌ័រជាបុរសជាច្រើន ជួបប្រទះការរំលោភបំពាន ដែលពួកគាត់ត្រូវបានហាមឃាត់មិនឲ្យស្លៀកសំលៀកបំពាក់ ដែលពួកគេពេញចិត្ត ហើយពួកគាត់ត្រូវបានផ្តល់ឲ្យនូវ ស្លៀកសំលៀកបំពាក់បែបមនុស្សស្រីនិងបង្ខំឲ្យស្លៀកតាមការចង់បានរបស់ឪពុកម្តាយវិញ។ **ពេជ្រ** អាយុ ២៦ឆ្នាំ ជាគិលានុបដ្ឋាយិកាបាននិយាយថា *"ម្តាយរបស់ខ្ញុំបានដកទូរសព្ទរបស់ខ្ញុំហើយឃុំខ្ញុំទុកនៅក្នុងផ្ទះ"*។

**ហាមមិនឲ្យស្លៀកសំលៀកបំពាក់ដែលគាត់ស្រឡាញ់**

**ហេង អាយុ ២៤ឆ្នាំ ជាស្ត្រីប្តូរយេនឌ័រជាបុរស**

**ហេង** មានអារម្មណ៍ថា គាត់មានលក្ខណៈ "ខុសប្លែក" ពីក្មេងស្រីដទៃនៅពេលដែលគាត់មានអាយុ ១៤ ឆ្នាំ។ គាត់បាននិយាយថា *"ពីដំបូង ខ្ញុំមានសម្ពាធខ្លាំងពីសំណាក់សមាជិកគ្រួសាររបស់ខ្ញុំ ពីព្រោះ ខ្ញុំចូលចិត្តស្លៀកពាក់បែបមនុស្សប្រុស។ គ្រួសាររបស់ខ្ញុំបានប្រមូលយកសំលៀកបំពាក់របស់ខ្ញុំទៅ បោះចោល បង្ខំខ្ញុំឲ្យស្លៀកពាក់ជាមនុស្សស្រីវិញ ភាគច្រើនគាត់ស្តីបន្ទោសខ្ញុំ ហើយឲ្យខ្ញុំធ្វើអ្វីដែលមនុស្សស្រីគួរតែធ្វើ។"* ពេលនោះគាត់មានការពិបាកយ៉ាងខ្លាំងក្នុងការធ្វើឲ្យម្តាយរបស់គាត់ បានយល់ពីគាត់ ប៉ុន្តែវាក៏ពិបាកខ្លាំងណាស់ដែរសម្រាប់ឪពុកម្តាយរបស់គាត់ក្នុងការទទួលស្គាល់កូនរបស់ខ្លួនក្នុងភាពជាខ្លួនឯង។ គាត់បាននិយាយាថា *"ខ្ញុំមានវិបត្តិយ៉ាងខ្លាំងនៅចំពោះមុខបញ្ហាដែលខ្ញុំកំពុងជួបប្រទះទាំងសម្ពាធនិងការបដិសេធពីឪពុកម្តាយរបស់ខ្ញុំ ហើយអ្វីដែលធ្វើឲ្យខ្ញុំឈឺចាប់បំផុតនោះ គឺពាក្យសម្តីដែលគាត់បានប្រើមកលើខ្ញុំ គឺគាត់ស្រែកដាក់ខ្ញុំថា គាត់សូមបន់កុំឲ្យមានកូនដូចជារូបខ្ញុំទៀត។"*

**ហាមឃាត់មិនឲ្យទៅសាលារៀន៖** មានស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ ស្ត្រីប្តូរយេនឌ័រជាបុរសមួយចំនួនបានសម្រេចចិត្តឈប់រៀន ដោយសារតែកត្តានិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ ប៉ុន្តែពុំបានរកឃើញចំណុចជាប់ទាក់ទងដោយផ្ទាល់ណាមួយពីគ្រួសារនៅក្នុងការសិក្សាស្រាវ ជ្រាវនោះទេ[2]។ **សីឡា អាយុ២៤ឆ្នាំ ជាស្ត្រីប្តូរយេនឌ័រជាបុរស**បាននិយាយថា *"គ្រួសាររបស់ខ្ញុំព្យាយាមបង្ខំខ្ញុំឲ្យប្តូរសាលា ព្រោះគាត់គិតថាមិត្តភក្តិនៅសាលារបស់ខ្ញុំ គឺជាមូលហេតុដែលធ្វើឲ្យខ្ញុំស្រលាញ់ស្រី"* ។ ស្រដៀងគ្នានេះដែរ **ម៉ាលីន អាយុ២៦ឆ្នាំ ជាស្ត្រីប្តូរយេនឌ័រជាបុរស និងជាអ្នករចនា**បាននិយាយថា *"ម្តាយរបស់ខ្ញុំគម្រាមខ្ញុំ មិនឲ្យខ្ញុំទៅសាលា ពីព្រោះគាត់ខ្លាចខ្មាស់គេ ដោយសារតែមានកូនដូចជារូបខ្ញុំ"* ។

2 ការបោះបង់ចោលសាលារៀនត្រូវបានកំណត់ថាជាការសំអាងដោយផ្ទាល់ទៅនឹងការសម្លុតគំរាមកំហែងរបស់សាលារៀនឬអាកប្បកិរិយាអវិជ្ជមានរបស់គ្រូបង្រៀនចំពោះសិស្សដែលជាស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ ស្ត្រីប្តូរយេនឌ័រជាបុរស ហើយវាត្រូវបានគេសន្មត់ថាមាតាបិតាជាច្រើនបានហាមឃាត់កូនរបស់ខ្លួនមិនឱ្យចូលសាលារៀន។ ទោះជាយ៉ាងណាក៏ដោយការសិក្សានេះមិនមានប្រមូលភ័ស្តុតាងគ្រប់គ្រាន់ដើម្បីវិភាគថា ហេតុផលអ្វី គឺជាកត្តាដ៏ខ្លាំងបំផុតដែលរារាំងកុមារ ក្រុមស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ ស្ត្រីប្តូរយេនឌ័រជាបុរស ពីការចូលរៀននោះ ទេ។ ភាគច្រើនប្រហែលជាការរួម បញ្ចូលគ្នានូវទម្រង់នៃការគាបសង្កត់ និងអំពើហឹង្សាច្រើនធ្វើឱ្យកុមារមិនចង់ទទួលបានការអប់រំ។

### ៣. *"ខ្ញុំដឹងថា គ្មាននរណាម្នាក់ចង់ធ្វើដូចជាខ្ញុំទេ" ផលប៉ះពាល់ពីអំពើហិង្សា*

ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ ស្ត្រីប្តូរយេនឌ័រជាបុរសចំនួន ៣០% ដែលមានអាយុក្រោម ៣៥ឆ្នាំ (សរុប ៣១នាក់) ដែលបានរកឃើញថា អ្នកខ្លះធ្លាប់បានគិតអំពីការធ្វើអត្តឃាត ដោយសារតែការបដិសេដមិនទទួលស្គាល់និន្នាការភេទ ឬ អត្តសញ្ញាណយេនឌ័ររបស់ពួកគាត់។ ការបាក់ទឹកចិត្តនិងការរើសអើងត្រូវបានកើតឡើងជាទូទៅទៅលើស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសផងដែរ។

**មិនទទួលបានការរាប់រកពីឪពុកម្តាយ ហើយម្តាយនិយាយថា វាជាការអាម៉ាស់ដែលមានកូនដូចគាត់**

**គៀត អាយុ ២៥ឆ្នាំ ជាស្ត្រីប្តូរយេនឌ័រជាបុរស និងមានអាជីពផ្នែកវេជ្ជសាស្ត្រ**

គៀត មានអាជីពផ្នែកវិជ្ជសាស្ត្រ បានចំណាយពេលអស់១០ឆ្នាំរស់នៅក្នុងភាពលាក់លៀម ទម្រាំតែគាត់មានភាពក្លាហានគ្រប់គ្រាន់ ក្នុងការបង្ហាញនូវអត្តសញ្ញាណយេនឌ័ររបស់គាត់ជាសាធារណៈ។ នៅពេលដែលគាត់បង្ហាញអត្តសញ្ញាណរបស់គាត់ទៅកាន់ឪពុកម្តាយរបស់គាត់ ពួកគាត់បានព្យាយាមកែប្រែគាត់ឲ្យក្លាយទៅជា មនុស្សស្រីវិញ។ ព្រោះតែមូលហេតុនេះគាត់បានព្យាយាមជាច្រើនលើកច្រើនសារក្នុងការកែប្រែខ្លួនឯងឲ្យក្លាយជាមនុស្សស្រី តែជាលទ្ធផលគាត់មិនអាចផ្លាស់ខ្លួនឯងបាននោះទេ។ គាត់បាននិយាយ អំពីបទពិសោធន៍ទាំងនោះថា *"ស្ទើរតែរាល់ពេល ឪពុកម្តាយរបស់ខ្ញុំមិនចង់រាប់រកខ្ញុំ ដោយសារតែខ្ញុំ មិនដូចជាមនុស្សស្រីដទៃ ជាពិសេសគឺមីងពូរបស់ខ្ញុំ និងអ្នកដែលនៅជុំវិញខ្ញុំ បើទោះបីជាកម្រិតការសិក្សារបស់ខ្ញុំថ្នាក់ឧត្តម ហើយចាប់ផ្តើមបើកគ្លីនីកឯកជនផ្ទាល់ខ្លួនក៏ដោយ ខ្ញុំនៅតែទទួលបានការ រើសអើងពីក្រុមគ្រួសារដដែល។* គាត់ថែមទាំងនិយាយថា *"ម្តាយរបស់ខ្ញុំនៅខ្មាសគេនៅឡើយដោយសារមានខ្ញុំជាកូន ហើយមានពេលខ្លះគាត់និយាយថា ចង់ឲ្យខ្ញុំមានលក្ខណៈជាមនុស្សស្រី ។"*

**ធីកា អាយុ៣៨ឆ្នាំ ជាស្ត្រីប្តូរយេនឌ័រជាបុរស** ធ្លាប់ត្រូវបានបង្ខំឲ្យរៀបការជាមួយបុរសដោយសារតែឪពុកម្តាយគាត់ព្យាយាមបំបែកគាត់ពីដៃគូរបស់គាត់។ គាត់បាននិយាយ *"ខ្ញុំសុខចិត្តស្លាប់ប្រសើរជាងរៀបការជាមួយមនុស្សប្រុស ដូច្នេះហើយការធ្វើអត្តឃាតគឺជាជម្រើសតែមួយគត់សម្រាប់ខ្ញុំ។"* ការបាក់ទឹកចិត្ត និងការរើសអើង គឺជាបញ្ហាមិនដាច់ស្រេច ហើយជាសុបិន្តអាក្រក់ដែលស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ ស្ត្រីប្តូរយេនឌ័រជាបុរសភាគច្រើនបានជួបប្រទះ ដែលជានិច្ចកាល ពួកគេត្រូវទប់ទល់ជាមួយនឹងបញ្ហា បែបនេះក្នុងជីវិតរបស់គេផងដែរ។ **ឈើណែត អាយុ២៥ឆ្នាំ ជាស្ត្រីប្តូរយេនឌ័រជាបុរស** បាននិយាយថា៖ *"ខ្ញុំដឹងថាគ្មាននរណាម្នាក់ចង់ធ្វើដូចខ្ញុំនោះទេ (ស្ត្រីប្តូរយេនឌ័រ) ប៉ុន្តែខ្ញុំមិនអាចកែប្រែខ្លួនឯងបានទេ។ នេះគឺជាខ្ញុំ"*

### ៤. *"ខ្ញុំបានព្យាយាមហើយ ប៉ុន្តែ....."៖ វិធីសាស្ត្រការពារខ្លួន ឬ ទបទល់*

ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ ទាំងពីរភេទ ស្ត្រីប្តូរយេនឌ័រជាបុរស បានរាយការណ៍ពីវិធីសាស្ត្រការពារខ្លួន ឬទបទល់ផ្សេងៗ ដើម្បីឆ្លើយតបទៅនឹង ភាពតានតឹងនិងការគៀបសង្កត់ ទាំងផ្នែកខាងក្នុង ឬខាងក្រៅ។ ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ ស្ត្រីប្តូរយេនឌ័រជាបុរស ភាគច្រើនបានព្យាយាមផ្លាស់ប្តូរ ឬកែប្រែខ្លួនឯង ដើម្បីឲ្យស្របទៅតាមទស្សនៈទូទៅនៃតួនាទីយេនឌ័រ ដែលសង្គមបានកំណត់ (ធ្វើខ្លួនឲ្យដូចជាស្រីពិត

ប្រាកដ) ឬ វិធីមួយទៀត គឺចាកចេញពីផ្ទះ ហើយចាប់ផ្តើមរស់នៅដោយឯករាជ្យ ខណៈដែលអ្នកខ្លះបានប្រើប្រាស់ប្រព័ន្ធបណ្តាញសង្គម ហើយមួយចំនួនបានរាយការណ៍ថា ប្រើប្រាស់ថ្នាំសម្រាប់ព្យាបាលជំងឺធ្លាក់ទឹកចិត្តធ្ងន់ធ្ងរដែលពួកគេជួបប្រទះដោយសារតែមានសម្ពាធអំពើហិង្សាពីគ្រួសារ។

**តារាងទី០១ វិធិសាស្ត្រការពារខ្លួន/ទប់ទល់**

| **វិធីសាស្ត្រការពារខ្លួន ឬ ទប់ទល់** | **សកម្មភាពអនុវត្តជាក់ស្តែង** |
|---|---|
| **ព្យាយាម "កែប្រែ"** | ស្ត្រីប្តូរភេទជាបុរសជាច្រើនបានព្យាយាមកែប្រែខ្លួនឯងតាមរយៈការព្យាយាមស្លៀកសំលៀកបំពាក់ជាមនុស្សស្រី ប៉ុន្តែជាទូទៅពួកគេបានលើកឡើងថា ទោះបីជាពួកគេព្យាយាមយ៉ាងណាក៏ដោយ ក៏ពួកគេមិនអាចធ្វើបានដែរ ដោយសារតែពួកគេដឹងថាពួក គេមិនអាចផ្លាស់ប្តូរ អត្តសញ្ញាណរបស់ខ្លួនឯងបានទេ។ |
| **សម្រេចចិត្តដើរចេញពីគ្រួសារ** | ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ ស្ត្រីប្តូរភេទជាបុរសជាច្រើនបានសម្រេចចិត្តដ៏ពិបាកក្នុងការចាកចេញពីឪពុកម្តាយរបស់ខ្លួន ដើម្បីមានសេរីភាពរួចផុតពីការគាបសង្កត់និងអំពើហិង្សាពីសមាជិកគ្រួសារ។ ស្ថិតនៅក្រោមបរិបទ វប្បធម៌នៅក្នុងសង្គមកម្ពុជា នៅពេលដែលកូនបានសម្រេចចិត្តថាដើរចេញពីគ្រួសារបែបនេះ គឺទាមទារឲ្យមានភាពក្លាហានច្រើននិងជាការសម្រេចចិត្តដ៏ធំមួយ។ |
| **ប្រព័ន្ធបណ្តាញសង្គមនិងការចងក្រងបណ្តាញ (ដូចជាអង្គការរ៉ក់)** | ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ ស្ត្រីប្តូរភេទជាបុរសជាច្រើននៅក្នុងការសិក្សាស្រាវជ្រាវនេះបានចែករំលែកថា អង្គការរ៉ក់បានធ្វើការចងក្រងបណ្តាញនិងអាចធ្វើឲ្យពួកគេ បានចែករំលែកទុក្ខព្រួយទៅវិញទៅមកហើយនិងឱកាសសំរាប់អានមិត្តភក្តិ ដែលធ្វើឲ្យពួកគេកាត់បន្ថយអារម្មណ៍ឯកា។ |

*៩. "កូនស្រីខ្ញុំមិនស្តាប់តាមបង្គាប់របស់ខ្ញុំសោះ" មូលហេតុនៃអំពើហិង្សា*

ខ្ញុំបានបដិសេធ(កូនដែលជាស្ត្រីប្តូរយេនឌ័រទៅជាបុរស) ហើយព្យាយាមបំបែកគាត់ពីដៃគូស្នេហារបស់គាត់។

**ម្តាយរបស់ស្ត្រីប្តូរយេនឌ័រជាបុរសអាយុ ៦៨ឆ្នាំ**

ការសិក្សាស្រាវជ្រាវបានធ្វើការកត់សម្គាល់ថាបុព្វហេតុចំបងបង្កឲ្យមានអំពើហិង្សាពីសំណាក់សមាជិកគ្រួសារ គឺជាអារម្មណ៍ **"អាម៉ាស់បំផុត"** សម្រាប់ឪពុកម្តាយដែលមានកូនជាស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស។ កត្តានេះ គឺបណ្តាលមកពីឪពុកម្តាយទទួលនូវឥទ្ធិពលនៃបទដ្ឋានយេនឌ័រតឹងរ៉ឹងចំពោះកូនស្រីនៅក្នុងប្រទេសកម្ពុជា ហើយទន្ទឹមនឹងបញ្ហាវប្បធម៌ ការយល់ដឹងរបស់ឪពុកម្តាយក៏នៅមានកម្រិតនៅឡើយ អំពីភាពចម្រុះនៃផ្លូវភេទ ឬភាពចម្រុះនៃយេនឌ័រ។ កត្តាទាំងអស់នោះ មានលក្ខណៈប្រទាក់ក្រឡាគ្នា ដែលជំរុញឲ្យមាន ការទទួលយកប្រព័ន្ធបិតាធិបតេយ្យ(ការប្រើប្រាស់អំណាចបុរស ដើម្បីគាបសង្កត់ទៅលើស្ត្រី) នៅក្នុងប្រទេសកម្ពុជា កាន់តែប្រកាន់យកនិងរក្សាថា ជារឿងធម្មតាដែលកត្តាទាំងនោះបានផាត់ចេញអ្នកណាដែលមិនព្រមប្រតិបត្តិតាមបទដ្ឋានយេនឌ័រតឹងរ៉ឹងនេះ។

*៩.១. អំពើហិង្សាដោយសារភាពអាម៉ាស់*

ឪពុកម្តាយនៅក្នុងប្រទេសកម្ពុជា ភាគច្រើនមានអារម្មណ៍ថា អាម៉ាស់នៅពេលដែលកូនស្រីរបស់ខ្លួនមិនព្រមប្រតិបត្តិទៅតាមបទដ្ឋានវប្បធម៌នៃតួនាទីយេនឌ័រនៅក្នុងសង្គម(សម្រាប់ក្មេងស្រី ឬ ស្ត្រី)ហើយការប៉ុនប៉ងកម្ចាត់ភាពអាម៉ាស់ចេញពីគ្រួសារ ឪពុកម្តាយភាគច្រើនបានជ្រើសរើសយកការប្រើប្រាស់អំពើហិង្សាទៅលើកូនៗរបស់ខ្លួន។ បន្ថែមលើសពីនេះ ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ(២០០៥) នៃប្រទេសកម្ពុជាអនុញ្ញាតឲ្យឪពុកម្តាយប្រើប្រាស់អំពើហិង្សាប្រឆាំងនឹងកុមារក្នុងគោលបំណង "ផ្តល់ជាដំបូន្មានប្រៀនប្រដៅនិងក្រើនរំឭក ឬសម្រាប់ជាការចង្អុរបង្ហាញជាដើម ដើម្បីឲ្យកូនៗដើរតាមគន្លងធម៌នៅក្នុងការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរតាមទំនៀមទំលាប់ និងប្រពៃណីរបស់ប្រទេស"(មាត្រា០៨)។ ជាមួយនឹងបរិបទនៃស្ថានភាពប្រពៃណីបែបនេះ នៅពេលដែលឪពុកម្តាយសង្កេតឃើញទង្វើរបស់កូនដែលមានលក្ខណៈខុសប្លែកធ្វើឲ្យឪពុកម្តាយមានអារម្មណ៍ថាអាម៉ាស់ ឬ ក៏ខ្មាស់គេ ឬក៏គិតថាកូនអាចនឹងបំផ្លាញកិត្តិយសរបស់គ្រួសារ ដែលទង្វើខុសឆ្គងទាំងនេះត្រូវបានបកស្រាយ នៅក្នុងរូបភាពកែតម្រូវដោយពួកគាត់ផ្ទាល់ទៅកាន់កូនៗ។

**"កូនស្រីខ្ញុំលែងស្តាប់បង្គាប់របស់ខ្ញុំ"**

រឿងរ៉ាវរបស់របស់លោកស្រី **សេរី អាយុ ៦៥ឆ្នាំ ជាម្តាយរបស់ស្ត្រីប្តូរយេនឌ័រជាបុរស**

**សេរី** បានបាត់បង់ប្តីរបស់គាត់នៅក្នុងសម័យខ្មែរក្រហមហើយគាត់មានកូន០៣នាក់រស់ក្នុងបន្ទុក ហើយគាត់ចិញ្ចឹមពួកគេរហូតដល់ពួកមានលទ្ធភាពអាចរស់នៅដោយខ្លួនឯងដោយចំណាយពេលអស់ ៣០ឆ្នាំ។ ដើរតួនាទីជាម្តាយផងនិងជាឪពុកផង គាត់បានព្យាយាមផ្គត់ផ្គង់ការនៅរបស់កូនៗនិងខ្លួនឯងទាំងលំបាក "ខ្ញុំមិនបានកត់សម្គាល់ទៅលើអត្តចរិតកូនស្រីរបស់ខ្ញុំនោះទេ(អត្តចរិតខុសប្លែកពីក្មេងស្រីដទៃ)នៅពេលដែលគាត់នៅក្មេង"។ លោកស្រី សេរី បានដឹងអំពីបញ្ហារបស់កូនស្រីដោយផ្ទាល់តាមរយៈការសារភាពរបស់កូនអំពីអត្តសញ្ញាណយេនឌ័ររបស់ខ្លួន ដែលគាត់តែងតែចង់ស្លៀកពាក់តាមបែបមនុស្សប្រុសនិងមានអត្តចរិតដូចមនុស្សប្រុស។ រំលឹកអំពីព្រឹត្តិការណ៍នេះ លោកស្រី សេរី បាននិយាយថា "នៅពេលនោះ ខ្ញុំពិតជាមានអារម្មណ៍ខឹងខ្លាំងណាស់ ពីព្រោះគាត់ហាក់ដូចជាផ្លាស់ប្តូរលឿនពេកទៅជាមនុស្សថ្មីម្នាក់ទៀត។ ជាពិសេសការស្លៀកពាក់របស់គាត់ធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលយ៉ាងខ្លាំង(ដោយស្លៀកពាក់ដូចជាមនុស្សប្រុស)។ ព្រោះតែកូនស្រីរបស់ខ្ញុំមិនស្តាប់តាមបង្គាប់ខ្ញុំ(ធ្វើដូចជាមនុស្សស្រីធម្មតា)។ ក្រោយមក ខ្ញុំក៏សម្រេចចិត្តឲ្យគាត់ចាកចេញពីផ្ទះ ដោយសារតែខ្ញុំយល់ថា នេះគឺជាវិធីតែមួយគត់ដែលអាចធ្វើឲ្យគាត់រីករាយជាមួយនឹងខ្លួនឯង។

### *៥.២. អំពើហិង្សាដោយសារបទដ្ឋានយេនឌ័រនិងសង្គម ដែលតឹងរ៉ឹងសម្រាប់ក្មេងស្រី និងស្ត្រីនៅក្នុងសង្គមកម្ពុជា*

សង្គមបិតាធិបតេយ្យ( យកបុរសជាធំ ) បានបង្ខំឲ្យក្មេងស្រីនិងស្ត្រី ចាំបាច់ត្រូវតែធ្វើតាម ក្បួនច្បាប់សង្គមដូចជាត្រូវចេះគោរពឪពុកម្តាយ និងថែរក្សាកិត្តិយសរបស់គ្រួសារ( MOWA, 2014 )។ ដូច្នេះហើយ ឪពុកម្តាយដែលមានកូនជាស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស ព្យាយាម "កែប្រែ" កូនស្រីរបស់ខ្លួនឲ្យប្រតិបត្តិទៅតាមក្បួនច្បាប់សង្គម។ ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស ជាច្រើនយល់ថា ពួកគេកំពុងទទួលទោសពីសង្គមដោយសារតែតែពួកគេខុសប្លែកពីគេឯង ហើយពួកគេត្រូវបានសមាជិកគ្រួសារប្រាប់ឲ្យជៀសវាងនូវអ្វីដែលមិនស្របទៅតាមយេនឌ័រសង្គមបានកំណត់។
**លីណែត អាយុ២០ឆ្នាំ ជាស្ត្រីស្រឡាញ់ស្ត្រី** ក៏និយាយផងដែរថា *"អំពីហិង្សាក្នុងគ្រួសារប្រឆាំងនឹងពួកយើង គឺដោយសារតែ បទដ្ឋានវប្បធម៌និងសង្គម"*។

### *៥.៣. អំពើហិង្សាដែលកើតឡើងពីការយល់ដឹងនូវមានកម្រិតអំពីភាពចម្រុះនៃផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ*

ទោះបីជាមានព័ត៌មានអំពីភាពចម្រុះគ្នានៃផ្លូវភេទនិងយេនឌ័របានផ្សព្វផ្សាយតាមរយៈបណ្ដាញសង្គមនៅក្នុងប្រទេសក៏ដោយ មនុស្សវ័យចំណាស់ដែលមានគំនិតអភិរក្សនិយមហើយនៅតែមិនអាចយល់បានអំពីមនុស្សដែលមិនធ្វើតាមបទដ្ឋានយេនឌ័រដែលសង្គមបានកំណត់សម្រាប់ភេទផ្ទុយគ្នា។ ឪពុកម្ដាយវ័យក្មេង(ក្នុងវ័យ៤០ឆ្នាំ ទៅ៥០ឆ្នាំ)ក៏គិតដូច្នោះដែរ។ ដូច្នេះនៅពេលដែលពួកគាត់បានឃើញមនុស្សដែលមាន "លក្ខណៈខុសប្លែក" ពួកគេនឹងធ្វើការរិះគន់ហើយបដិសេធភ្លាមៗ រាប់ទាំងឪពុកម្ដាយដែលមានកូនជាស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្ដូរយេនឌ័រជាបុរស ។

### *៦. អនុសាសន៍*

"ក្រសួងកិច្ចការនារី តែងតែទទួលស្គាល់អំពីបញ្ហាប្រឈមនិងការព្រួយបារម្ភរបស់ស្ត្រីស្រឡាញ់ ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្ដូរយេនឌ័រជាបុរស ហើយយើងតែងតែរិះរកគម្រោងល្អៗ ដើម្បី គាំទ្រពួកគេ។ ពួកយើងតែងតែសួរថា "អ្វីទៅដែលជាបញ្ហារបស់ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរ ភេទ និងស្ត្រីប្ដូរយេនឌ័រជាបុរស? តើអ្វីជាតម្រូវការរបស់ពួកគេ? ហើយអ្វីខ្លះដែលក្រសួងរបស់យើង អាចធ្វើអ្វីបានសម្រាប់ពួកគេ? ដើម្បីធ្វើឲ្យការគាំទ្រមានប្រសិទ្ធិភាព ពួកយើងត្រូវការការសិក្សាស្រាវ ជ្រាវបន្ថែមទៀតជាមួយនឹងភស្ដុតាងច្បាស់លាស់ ដើម្បីអភិវឌ្ឍចេញជាគម្រោង ឬ យុទ្ធសាស្ត្រល្អ សម្រាប់ការផ្លាស់ប្ដូរវិជ្ជមាននៅក្នុងសង្គមរបស់យើង។"

**តំណាងក្រសួងកិច្ចការនារី នៃប្រទេសកម្ពុជា**

ទោះបីជាមានការខិតខំប្រឹងប្រែងក្នុងធ្វើឲ្យស្ថានរបស់ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្ដូរយេនឌ័រជាបុរសមានភាពប្រសើរឡើងយ៉ាងណាក៏ដោយ ក៏ប្រទេសកម្ពុជានៅតែជួបប្រទះ ជាមួយនឹងបញ្ហាប្រឈមជាច្រើន ដែលកំពុងបន្តគាបសង្កត់ទៅលើ សិទ្ធិជាមូលដ្ឋានក្នុងការរស់នៅរបស់ពួកគេ។ ហេតុដូចនេះ ការសិក្សាស្រាវជ្រាវនេះសូមលើកយកនូវអនុសាសន៍ចំនួន០៩ សម្រាប់ឲ្យរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័នពាក់ពន្ធ័អាចធ្វើការសិក្សាពិចារណា ដើម្បីធ្វើឲ្យប្រជាជន និងមជ្ឈដ្ឋានសាធារណៈបាន ដឹងនិងយល់អំពីភាពចម្រុះនៃផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ។ អនុសាសន៍ទាំងនេះ នឹងបែងចែកជា ពីរប្រភេទ៖ **ទីមួយ** គឺ អនុសាសន៍តម្រង់ទិសរយៈពេលខ្លី ដែលត្រូវតែចាត់វិធានការជាបន្ទាន់ និង**ទីពីរ** អនុសាសន៍តម្រង់ទិសរយៈពេលវែង ដែលត្រូវធ្វើឲ្យបានដល់ត្រឹមឆ្នាំ២០២៣ ឲ្យស្របទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលមានគោលដៅទី៥ ដោះស្រាយបញ្ហាសមភាពយេនឌ័រ ជាមួយនឹងគោលការណ៍មូលដ្ឋានមួយដែលកំណត់ថា មិនត្រូវទុកនរណាម្នាក់ចោលនោះទេ។ សម្រាប់អនុសាសន៍សម្រាប់រយៈពេលវែង គឺជាអនុសាសន៍ដែលបានមកពី របាយការណ៍ត្រួតពិនិត្យជាសកលតាមកាលកំណត់(UPR) នៅក្នុងខែកុម្ភៈ ឆ្នាំ ២០១៩។

## ៦.១. អនុសាសន៍រយៈពេលខ្លី

### ១. បង្កើនការយល់ដឹងនិងសមត្ថភាពរបស់អ្នកសង្គមកិច្ច អំពីនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ

ការសិក្សាស្រាវជ្រាវនេះបានរកឃើញនូវទម្រង់ផ្សេងៗនៃអំពើហិង្សាទៅលើ ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស ហើយជាលទ្ធផលអំពើហិង្សាទាំងនេះ បានរុញច្រានពួកគាត់ឲ្យកាន់តែរងគ្រោះពីការមាក់ងាយ ការមិនយកចិត្តទុកដាក់ និងអារម្មណ៍រស់នៅដោយឯកោ។ ពួកគាត់ត្រូវការការប្រឹក្សាយោបល់ផ្លូវចិត្តប្រកបដោយវិជ្ជាជីវៈនិងផ្អែកលើគោលការណ៍សិទ្ធិជាមូលដ្ឋាន ដើម្បីស្តារសេចក្តីថ្លៃថ្នូរនិងភាពវិជ្ជមាននៅក្នុងជីវិតរបស់ពួកគាត់ឡើងវិញ ហើយប្រភេទសេវាកម្មបែបនេះគួរត្រូវបានពង្រីកនៅទូទាំងប្រទេសកម្ពុជា។ បុគ្គលិកសង្គមកិច្ច ដែលជ្រើសរើសដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវតែមានជំនាញបន្ថែមទៀត ទៅលើការពិគ្រោះយោបល់ នៃការប៉ះទង្គិចផ្លូវចិត្ត ទាក់ទងនឹង និន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញ យេនឌ័រ។

### ២. ពង្រីកការទទួលបាននូវសេវាប្រឹក្សាយោបល់ផ្លូវចិត្ត

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ(គ.ក.ស.ក)នៅកម្រិតឃុំ/សង្កាត់ដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់ស្ត្រីនិងកុមារដែលត្រូវការជំនួយនៅក្នុងទម្រង់ផ្សេងៗ។ ដូច្នេះ ក្រសួងមហាផ្ទៃសហការជាមួយនឹងក្រសួងកិច្ចការនារី ត្រូវចាត់វិធានការជាបន្ទាន់ក្នុងការបំពាក់បំប៉នចំណេះដឹងទាក់ទងនឹងនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ ដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ និងគ.ក.ស.ក។

### ៣. ប្រើប្រាស់បណ្តាញផ្សព្វផ្សាយ(ទូរទស្សន៍ជាតិឬវិទ្យុជាតិ) ដើម្បីបង្កើនការយល់ដឹងអំពីនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ ដើម្បីផ្លាស់ប្តូរអាកប្បកិរិយាប្រកបដោយវិជ្ជមាន

ការផ្លាស់ប្តូរបទដ្ឋានសង្គមដែលរើសអើងភាពចម្រុះគួរតែត្រូវបានកែប្រែ ហើយនៅក្នុងបដិវត្តន៍ឧស្សាហ៍កម្មជំនាន់ទី៤នេះ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម គឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធិភាពក្នុងការធ្វើឲ្យប្រជាជនទូទៅបានស្វែងយល់បន្ថែមនិងរួមគ្នា ដើម្បីគាំទ្រភាពចម្រុះ នៃនិន្នាការ ឬ ទំនោរភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ។ ដោយសារតែរាជរដ្ឋាភិបាលកម្ពុជា មានកម្មសិទ្ធិលើស្ថានីយទូរទស្សន៍ជាតិនិងវិទ្យុជាតិ ហេតុដូចនេះហើយ យើងពិតជាចង់ឲ្យមានការចាត់វិធានការភ្លាមៗ ដើម្បីពង្រីកការផ្សព្វផ្សាយអំពី និន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ តាមរយៈការសហការគ្នារវាង អង្គការមិនមែនរដ្ឋាភិបាលដូចជា អង្គការសហគមន៍ឥន្ទធនូកម្ពុជា(រ៉ក់) និង

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដែលធ្លាប់បង្កើតឲ្យមានការតស៊ូមតិ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីបញ្ហាទាំងនេះទៅដល់មនុស្សគ្រប់វ័យ។ លើសពីនេះទៅទៀត ក្រសួងព័ត៌មាន គួរតែពិចារណាដាក់ឲ្យអនុវត្តនូវក្រមសីលធម៌សារព័ត៌មាន ដើម្បីជានាមិនឲ្យមានការផ្សព្វផ្សាយដោយប្រើប្រាស់ពាក្យសម្តីឬសកម្មភាពដែលមានលក្ខណៈរើសអើង មាក់ងាយ និងអវិជ្ជមានដល់ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស។

## ៤. ផ្សព្វផ្សាយយន្តការបណ្តឹងនិងធ្វើឲ្យយន្តការនៅជិត ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (គ.ស.ម.ក) បានបង្កើតយន្តការរាយការណ៍ដើម្បីនាំយកករណីការរំលោភបំពានសិទ្ធិមនុស្ស។ ប៉ុន្តែ ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ ស្ត្រីប្តូរយេនឌ័រជាបុរសមិនសូវបានដឹងអំពីយន្តការនេះទេ។ ទោះជាវាមានលក្ខណៈពិបាកសម្រាប់ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ ស្ត្រីប្តូរយេនឌ័រជាបុរសក្នុងការរាយការណ៍អំពីការរំលោភបំពានសិទ្ធិមនុស្សដែលបានធ្វើឡើង ដោយសមាជិកគ្រួសាររបស់ពួកគាត់ក៏ដោយ យ៉ាងហោចណាស់ គ.ស.ម.ក អាចចាត់វិធានការសកម្មបន្ថែមទៀត ដើម្បីនាំសេវាកម្មនិងយន្តការនេះជូនដល់សហគមន៍ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រ ដើម្បីផ្តល់ឱកាសដល់ពួកគាត់ទទួលបានយុត្តិធម៌តាមរយៈយន្តការថ្នាក់ជាតិដែលមានស្រាប់។

## ៥. ផ្តល់វគ្គបណ្តុះបណ្តាលអំពើហិង្សាគ្រួសារប្រឆាំងស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរភេទយេនឌ័រជាបុរសដល់មន្ត្រីអនុវត្តច្បាប់និងមន្ត្រីតុលាការ

អំពើហិង្សាគ្រួសារ គឺជាផ្នែកមួយនៃអំពើហិង្សាក្នុងគ្រួសារ ប៉ុន្តែអំពើហិង្សាប្រភេទនេះ មិនត្រូវបានគេរាយការណ៍ ឬមិនត្រូវបានដឹងឮដល់មន្ត្រីអនុវត្តច្បាប់ឬមន្ត្រីតុលាការទេ (ចៅក្រម ព្រះរាជអាជ្ញា និងតុលាការ)។ ជាមួយនឹងតួនាទី របស់ក្រសួងយុត្តិធម៌ ក្នុងផ្តល់ចំណេះដឹង ផ្នែកច្បាប់តាមរយៈវគ្គបណ្តុះបណ្តាលច្បាប់ដល់មន្ត្រីពាក់ព័ន្ធនឹងច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារក្រសួងគប្បីត្រូវជានាឲ្យមានការដាក់បញ្ចូលប្រធានបទនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ នោះចូលទៅក្នុងកម្មវិធីវគ្គបណ្តុះបណ្តាលនោះផងដែរ និងអំពើហិង្សាគ្រួសារ ដែលកើតឡើងដោយសារ និន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ របស់ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស។

### ៦. បង្កើតឲ្យមានការសិក្សាស្រាវជ្រាវបន្ថែមទៀតអំពីបញ្ហារបស់ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទនិងស្ត្រីប្តូរយេនឌ័រជាបុរសពីសំណាក់អាជ្ញាធររដ្ឋ អ្នកសិក្សាជាន់ខ្ពស់ និងអង្គការមិនមែនរដ្ឋាភិបាល

ការសិក្សាស្រាវជ្រាវបន្ថែមត្រូវបានគេជំរុញដើម្បីស្វែងយល់ឲ្យបានស៊ីជម្រៅអំពីបញ្ហាទាក់ទងនឹងស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស។ ការសិក្សាស្រាវជ្រាវបែបនេះគួរតែត្រូវធ្វើឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងកិច្ចការនារី ក្នុងការបង្កើតភស្តុតាងដែលមានសារៈសំខាន់ដល់ការបង្កើនប្រសិទ្ធិភាពនិងភាពរឹងមាំដល់ការបង្កើតគោលនយោបាយបញ្ឈប់ការរើសអើងនិងអំពើហិង្សា មកលើស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស។ បន្ថែមពីនេះ មានតែព័ត៌មានបន្តិចបន្តួចប៉ុណ្ណោះដែលបានដឹងអំពីបញ្ហាសុខភាពរបស់ស្ត្រីប្តូរយេនឌ័រជាបុរស កំពុងតែជួបប្រទះ(គួយ៉ាងពួកគាត់ភាគច្រើន មិនសូវចូលចិត្តទៅ ពិនិត្យសុខភាពបន្តពូជ ដោយសារតែពួកគាត់គិតថាពួកគាត់គឺជាបុរស)។ ម៉្យាងវិញទៀត ការសិក្សាលើអំពើហិង្សាក្នុងគ្រួសាររវាងដៃគូស្នេហាភេទដូចគ្នា មិនធ្លាប់ត្រូវបានគេធ្វើការសិក្សានោះទេ ដែលនាំឲ្យមិនមានការវិភាគទិន្នន័យណាមួយ ទាក់ទងនឹងឥទ្ធិពលសាសនា មកលើភាពចម្រុះនៃផ្លូវភេទ ក្នុងបរិបទប្រទេសកម្ពុជា។ មិនត្រឹមតែរាជរដ្ឋាភិបាលប៉ុណ្ណោះទេដែលគួរបង្កើតឲ្យមានការសិក្សាស្រាវជ្រាវ អង្គការមិនមែន រដ្ឋាភិបាលដែលធ្វើការទាក់ទងជាមួយនឹងការពង្រឹងភាពម្ចាស់ការឬ សិទ្ធិអំណាចស្ត្រី ក៏អាចចូលរួមបន្ថែមទស្សនទានទៅលើបញ្ហារបស់ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស តាមរយៈការសិក្សាស្រាវជ្រាវផងដែរ។ ទន្ទឹមនឹងនេះ ស្ថាប័នសិក្សាជាន់ខ្ពស់ ដូចជាសាកលវិទ្យាល័យចាំបាច់គួរតែពិចារណាដាក់វិធានការសកម្មមួយចំនួន ដើម្បីរៀបចំឲ្យអ្នកស្រាវជ្រាវអាចបញ្ជ្រាបការយល់ដឹងទាក់ទិននឹងបញ្ហា ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រដែលត្រូវបានស្ថាប័នសិក្សាមើលរំលងនៅក្នុងប្រទេសកម្ពុជា។

## ៦.២. អនុសាសន៍រយៈពេលវែង

### ១. អនុម័តច្បាប់ស្តីអំពីការប្រឆាំងនឹងការរើសអើង

បើទោះជាការរើសអើងត្រូវបានហាមឃាត់នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានិងនៅក្នុងច្បាប់ជាតិដទៃទៀត ក៏ដូចជាមានចែងនៅក្នុងច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិដែលកម្ពុជាបានចុះហត្ថលេខាទទួលអនុវត្តក្តី កម្ពុជាមិនទាន់បានអនុម័តច្បាប់ប្រឆាំងការរើសអើងគ្រប់ជ្រុងជ្រោយមួយនៅឡើយទេ ដែលច្បាប់នោះសំដៅហាមឃាត់ការរើងអើង ដោយផ្អែកទៅលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រផងដែរ។ ការអនុម័តទៅលើច្បាប់ពិសេសប្រភេទនេះ អាចធ្វើឲ្យសាធារណជនបានដឹងថា រដ្ឋកំពុងតែអនុវត្តវិធានការសកម្មក្នុងការលុបបំបាត់ការរើសអើងចំពោះ ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស និងប្រជាជនងាយរងគ្រោះដទៃទៀត។ ក្រសួង

យុត្តិធម៌គួរតែ បង្កើតការពិភាក្សាជុំវិញបញ្ហានេះបន្ថែមទៀត ហើយត្រូវផ្តួចផ្តើមរៀបចំនូវសេចក្តីព្រាងច្បាប់មួយនេះ ដោយសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល ប្រកបដោយតម្លាភាព ។

## <u>២. អនុញ្ញាតឲ្យស្ត្រីប្តូរយេនឌ័រជាបុរស ពួកគេផ្លាស់អត្តសញ្ញាណយេនឌ័ររបស់ខ្លួននៅក្នុងអត្តសញ្ញាណប័ណ្ណ</u>

មានស្ត្រីប្តូរយេនឌ័រទៅជាបុរសជាច្រើនបានស្នើសុំឲ្យរដ្ឋាភិបាលកម្ពុជាអនុញ្ញាតឲ្យពួកគេបានផ្លាស់ប្តូរអត្តសញ្ញាណយេនឌ័ររបស់ខ្លួនពីស្រីមកប្រុសវិញនៅក្នុងអត្តសញ្ញាណប័ណ្ណ ដើម្បីធ្វើពួកគេមានអារម្មណ៍ថារស់នៅជាមួយនឹងការពិតរបស់ខ្លួនឯង និងព្រមទាំងអាចបានរៀបការជាមួយនឹងមនុស្សដែលពួកគេជ្រើសរើស។ ប្រទេសជាច្រើននៅលើពិភពលោកបានអនុញ្ញាតឲ្យដំណើរការស្របច្បាប់សម្រាប់បុគ្គលផ្លាស់ប្តូរយេនឌ័រ ហើយប្រទេសកម្ពុជាអាចយកគំរូពីប្រទេសទាំងនោះក្នុងការបង្កើតច្បាប់ប្រភេទនេះបាន។ ក្រសួងយុត្តិធម៌ គួរតែគិតពិចារណាជាបន្ទាន់ក្នុងការផ្តួចផ្តើមរៀបចំឲ្យមានដំណើរការមួយនេះ។

## <u>៣. អនុញ្ញាតឲ្យមនុស្សគ្រប់គ្នាបានរៀបការជាមួយនឹងបុគ្គលដែលពួកគេជ្រើសរើសដោយមិនគិតអំពីភេទឬយេនឌ័រ</u>

ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសភាគច្រើន បានស្នើសុំឲ្យមានការអនុញ្ញាតឲ្យពួកគេបានរៀបការដោយស្របច្បាប់ជាមួយនឹងមនុស្សដែលគេស្រឡាញ់ ដោយមិនគិតអំពីនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ។ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា បានធានានូវសមភាព ហើយគោលការណ៍នេះ គួរតែត្រូវអនុវត្តទៅលើមនុស្សគ្រប់រូប។ អនុញ្ញាតឲ្យពួកគេបានបង្កើតគ្រួសារ ដែលទទួលស្គាល់ដោយស្របច្បាប់និងអាច ឲ្យពួកគាត់សុំកូន តាមសេចក្តីត្រូវការរបស់ប្រជាជនដែលជាស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រផងដែរ។ ក្រសួងយុត្តិធម៌ គួរតែផ្តួចផ្តើមពិភាក្សាអំពីវិសោធនកម្មលើច្បាប់ដែលចាំបាច់ដែលរួមមានក្រមរដ្ឋប្បវេណី ដើម្បីការពារសិទ្ធិស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស ដូចសិទ្ធិពលរដ្ឋ ដទៃផងដែរ។

### *៧. សេចក្តីសន្និដាន៖ ពហុប្រព័ន្ធនៃការគាបសង្កត់*

រឿងរ៉ាវជីវិតផ្ទាល់ខ្លួនជាច្រើនរបស់ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសនៅក្នុងការសិក្សាស្រាវជ្រាវ បានផ្តល់នូវភស្តុតាងជាច្រើន ដែលបង្ហាញថា ពួកគេកំពុងតែប្រឈមនឹងអំពើហិង្សាយ៉ាងធ្ងន់ធ្ងរនៅក្នុងលំនៅដ្ឋានរបស់ពួកគេ។ រឿងរ៉ាវ ដែលបានលើកឡើងនៅក្នុងការសិក្សាមួយនេះ បានបង្ហាញយ៉ាងជាក់ច្បាស់អំពីរបៀបដែលធ្វើឲ្យពួកគេមានអារម្មណ៍ថាផ្ទះរបស់ខ្លួនឯងបានក្លាយទៅជាកន្លែងលែងមានសុវត្ថិភាព និងមិនអាចឲ្យពួកគេអាចរស់នៅបានតទៅទៀត។ សម្រាប់ពួកគេផ្ទាល់គ្រួសារគឺជាកន្លែងចាប់ផ្តើមដំបូងបំផុតដែលធ្វើឲ្យពួកគេមានបទពិសោធន៍នឹងអំពើហិង្សា។ អំណាចនៃប្រព័ន្ធបិតាធិបតេយ្យ(ការ

អំណាចបុរសជាធំ)នៅក្នុងប្រទេសកម្ពុជា បានបង្កើតឲ្យមានការគាបសង្កត់ធ្ងន់ធ្ងរមកលើ ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស នៅក្នុងរូបភាពជាច្រើនផ្សេងៗគ្នា ហើយមិនអាចធ្វើឲ្យពួកគេអាចរកឃើញកន្លែងមួយមានសុវត្ថិភាពសម្រាប់រស់នៅបាន សូម្បីតែនៅក្នុងផ្ទះរបស់ខ្លួនឯង។

ការស្រាវជ្រាវកាលពីមុន បានសង្កត់ធ្ងន់ទៅលើការរើសអើង និងការប្រើប្រាស់អំពើហិង្សា ប្រឆាំងនឹងស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសនៅទីសាធារណៈ ដែលតាមរយៈការសិក្សាស្រាវជ្រាវទាំងនោះក៏បានបង្ហាញនូវចំនួន(ប្រេវ៉ាឡង់)និងផលប៉ះពាល់នៃអំពើហិង្សាគ្រួសារ។ ប៉ុន្តែការសិក្សាស្រាវជ្រាវនេះ បានកត់ត្រានូវទម្រង់ផ្សេងៗនៃអំពើហិង្សាដែលស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសភាគច្រើនទទួលរងពីសំណាក់សមាជិកគ្រួសាររបស់ខ្លួនផ្ទាល់។ ផ្ទះគ្រួសារគួរតែជាកន្លែងដែលមានសុវត្ថិភាពសម្រាប់មនុស្សគ្រប់គ្នា ជាពិសេសកូនៗដែលត្រូវការសេចក្តីស្រលាញ់និងភាពកក់ក្តៅពីឪពុកម្តាយខ្លួន ដើម្បីភាពលូតលាស់របស់ពួកគេ។ វាមានភាពចាំបាច់ណាស់ដែលយើងត្រូវធ្វើ ដើម្បីពង្រឹងភាពម្ចាស់ការទៅដល់ក្រុមគ្រួសារនៅក្នុងប្រទេសកម្ពុជាបានទទួលយកនូវភាពចម្រុះគ្នា តាមរយៈការទទួលស្គាល់ភាពខុសៗគ្នារបស់មនុស្ស ហើយវាគឺជារឿងដែលខុស ក្នុងការដែលរើសអើងប្រឆាំងនឹងស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស ដោយសារថាពួកគេជានរណាហើយស្រលាញ់អ្នកណានោះ។

*"ខ្ញុំសង្ឃឹមថាមនុស្សជំនាន់ក្រោយនឹងត្រូវបានផ្តល់ព័ត៌មានឲ្យបានគ្រប់គ្រាន់ ដើម្បីស្វែងយល់អំពីខ្លួនឯងឲ្យបានពិតប្រាកដ ហើយត្រូវតែមានទំនុកចិត្តចំពោះខ្លួនឯងនិងមានសេរីភាពនៅក្នុងការបង្ហាញអំពីភាពជាខ្លួនឯង។"*

**វ៉ាត់ អាយុ៤៨ឆ្នាំ ជាស្ត្រីប្តូរយេនឌ័រជាបុរស**

*ឧបសម្ព័ន្ធទី១ គោលបំណង គោលដៅ និងមធ្យោបាយក្នុងការសិក្សាស្រាវជ្រាវ*

### ១. គោលបំណងនៃការសិក្សានេះ

ការសិក្សាស្រាវជ្រាវនេះមានបំណងចងក្រងរឿងរ៉ាវនៃការរើសអើងក្នុងគ្រួសារទៅលើស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ ស្ត្រីប្តូរយេនឌ័រជាបុរស ដើម្បីធ្វើជាភស្តុតាងសម្រាប់តស៊ូមតិជាមួយអ្នករៀបចំតាក់តែងច្បាប់និងគោលនយោបាយក្នុងគោលបំណងបង្កើនការចាប់អារម្មណ៍លើចំណុចនេះ ហើយក៏ដើម្បីជះឥទ្ធិពលវិជ្ជមានដល់ការកែប្រែច្បាប់និងគោលនយោបាយ ដើម្បីការពារសិទ្ធិរបស់ពួកគាត់។ គោលដៅសំខាន់ៗជាពិសេសបន្ថែមទៀតនៃការសិក្សានេះគឺដើម្បី៖

- ចែករំលែករឿងរ៉ាវនិងបទពិសោធន៍នៃអំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ ស្ត្រីប្តូរយេនឌ័រជាបុរស ក្នុងចំណោមសមាជិករបស់សហគមន៍ឥន្ទធនូកម្ពុជា ដើម្បីជំរុញនិងលើកទឹកចិត្តដល់ពួកគាត់។
- ប្រាប់ដល់សាធារណជនអំពើហិង្សាក្នុងគ្រួសារប្រឆាំងនឹងស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស ព្រមទាំងផលប៉ះពាល់ផ្សេងៗ ដើម្បីឲ្យពួកគេ ទទួលបាននូវចំណេះដឹងបន្ថែមទៀតទាក់ទងនឹងសិទ្ធិមនុស្សជាសកលនិងគោលការណ៍ នៃការមិនរើសអើង ដោយផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។
- នាំយកភស្តុតាងនៃការរើសអើងលើសហគមន៍ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ ស្ត្រីប្តូរយេនឌ័រជាបុរស ក្នុងការតស៊ូមតិជាមួយអ្នករៀបចំតាក់តែងច្បាប់និងគោលនយោបាយ ឲ្យយកចិត្តទុកដាក់ចំពោះបញ្ហានេះ ធ្វើយ៉ាងណាជះឥទ្ធិពលជាវិជ្ជមានដល់ការកែប្រែច្បាប់និងគោល ដើម្បីការពារសិទ្ធិរបស់ពួកគេ។

### ២. ភូមិសាស្ត្រនិងក្របខណ្ឌនៃការសិក្សា

#### ២.១. តំបន់គោលដៅ

នៅក្នុងការសិក្សាស្រាវជ្រាវនេះ អង្គការសហគមន៍ឥន្ទធនូកម្ពុជាបានជ្រើសរើសយក ខេត្តចំនួន០៨ ជាខេត្តអទិភាពរួមមាន៖ ភ្នំពេញ សៀមរាប ស្ទឹងត្រែង ត្បូងឃ្មុំ ព្រះសីហនុ ព្រៃវែង ពោធិ៍សាត់ និងកណ្តាល។

#### ២.២. ក្រុមគោលដៅ

ដំបូងគេរំពឹងថាការសិក្សាស្រាវជ្រាវនេះ ជ្រើសរើសយកអ្នកចូលរួម ចំនួន៨០នាក់ ដែលជាស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ ស្ត្រីប្តូរយេនឌ័រជាបុរស មានអាយុពី១៨ដល់៣៥ឆ្នាំ សមាជិកគ្រួសាររបស់ពួកគេចំនួន១០នាក់ ដែលបានផ្លាស់ប្តូរឥរិយាបថជាវិជ្ជមានចំពោះកូនស្រីដែលមាននិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រជា ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ ស្ត្រីប្តូរយេនឌ័រជាបុរស។ ប៉ុន្តែទោះជាអង្គការរ៉េកបានរៀបចំចំនួនអ្នកចូលរួមលើសពី៨០នាក់ក៏ដោយ ក៏នៅទីបញ្ចប់មានតែអ្នកចូលរួមដែលជា ស្ត្រីស្រឡាញ់

ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ ស្ត្រីប្តូរយេនឌ័រជាបុរស ចំនួន៦១នាក់ប៉ុណ្ណោះ ដែលយល់ព្រមជួបជាមួយអ្នកស្រាវជ្រាវ។ មិនតែប៉ុណ្ណោះ ការសម្ភាសន៍ឪពុកម្តាយរបស់ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ ស្ត្រីប្តូរយេនឌ័រជាបុរស មានការលំបាក ដែលអាចឲ្យក្រុមអ្នកស្រាវជ្រាវបានជួបតែ ០៣នាក់ប៉ុណ្ណោះ។ លើសពីនេះទៅទៀត ក្រុមអ្នកស្រាវជ្រាវក៏មានគម្រោងសម្ភាសន៍តំណាងភ្នាក់ងារសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធររាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើតឲ្យបានអនុសាសន៍ដ៏ពេញលេញគ្រប់ជ្រុងជ្រោយសម្រាប់ការផ្លាស់ប្តូរច្បាប់និងគោលនយោបាយ។ បញ្ជីឈ្មោះអ្នកចូលរួមមាននៅក្នុងឧបសម្ព័ន្ធទី២។

| លេខរៀង | ទីក្រុងឬខេត្ត | ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ ស្ត្រីប្តូរយេនឌ័រជាបុរស | សមាជិកគ្រួសារ | អ្នកចូលរួមសំខាន់ * | សរុប |
|---|---|---|---|---|---|
| ០១ | ភ្នំពេញ | ២៥ | ២ | ១២ | ៣៩ |
| ០២ | កណ្តាល | ២ | | | ២ |
| **តំបន់ទន្លេសាប** | | | | | |
| ០៣ | សៀមរាប | ៤ | 0 | | ៤ |
| ០៤ | ពោធិ៍សាត់ | ៥ | | ១ | ៦ |
| **តំបន់ទំនាប** | | | | | |
| ០៥ | ព្រៃវែង | ១១ | 0 | | ១១ |
| ០៦ | ត្បូងឃ្មុំ | ៥ | 0 | ១ | ៦ |
| **តំបន់ឆ្នេរ** | | | | | |
| ០៧ | ព្រះសីហនុ | ៥ | ១ | ១ | ៧ |
| **តំបន់ខ្ពង់រាប** | | | | | |
| ០៨ | ស្ទឹងត្រែង | ៤ | | | ៤ |
| **សរុប** | | **៦១** | **០៤** | **១៥** | **៧៩** |

## ៣. មធ្យោបាយក្នុងការសិក្សាស្រាវជ្រាវ

### ៣.១. វិធីសាស្ត្រសម្រាប់ការប្រមូលទិន្នន័យ

មធ្យោបាយសម្រាប់ប្រមូលទិន្នន័យ គឺផ្អែកលើគោលការណ៍បរិយាប័ន(ការរួមបញ្ចូល) ការចូលរួម និងសិទ្ធិជាមូលដ្ឋាន។ ការយកចិត្តទុកដាក់ជាពិសេសលើគោលនយោបាយការពារសិទ្ធិកុមារនិងក្រមសីលធម៌របស់អង្គការរ៉ក់នៅក្នុងការសម្ភាសន៍ក្រុមគោលដៅ។ ការសិក្សាស្រាវជ្រាវនេះមានការចូលរួម តាមរយៈដំណើរ

ការរៀបចំការសិក្សាស្រាវជ្រាវ ការប្រមូលទិន្នន័យ ហើយនិងការវិភាគទិន្នន័យផងដែរ ដែលក្រុមការងារអង្គការរ៉ក់ បានចូលរួមចំណែកយ៉ាងសំខាន់ ។

នៅក្នុងការសិក្សាស្រាវជ្រាវ គេបានប្រើប្រាស់វិធីសាស្ត្រគុណភាព (ដោយមានការសម្ភាសន៍ពាក់កណ្ដាលរៀបចំ) ដើម្បីប្រមូលព័ត៌មានផ្ដល់ឲ្យដោយអ្នកចូលរួម ជាពិសេសក្រុមស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្ដូរយេនឌ័រជាបុរស នូវឱកាសក្នុងការរៀបរាប់ពីសេចក្ដីសុខ ភាពសប្បាយរីករាយ ទុក្ខព្រួយ បញ្ហា និងក្ដីសង្ឃឹមសម្រាប់អនាគតរបស់ពួកគេ។ លើសពីនេះទៅទៀត ទិន្នន័យគុណភាពនេះត្រូវបានប្រមូល ដើម្បីបង្ហាញអំពីបញ្ហាជាច្រើន ក្នុងចំណោមអ្នកចូលរួមនៅក្នុងការសិក្សាស្រាវជ្រាវនេះ ប៉ុន្តែវាត្រូវបានកម្រិតដោយសារតែទំហំគំរូតូចពេកសម្រាប់ការសិក្សានេះ។

មធ្យោបាយដ៏មានសារៈសំខាន់ផ្សេងទៀតដែលត្រូវបានអនុវត្តក្នុងការប្រមូលទិន្នន័យនោះ គឺមានរៀបរាប់ខាងក្រោម៖

- ការពិនិត្យមើលឯកសារ៖ ឯកសារស្រាវជ្រាវសំខាន់ៗទាក់ទងនឹងអ្នកស្រលាញ់ភេទដូចគ្នា (LGBTIQ)។
- ការចុះសម្ភាសន៍/ការសម្ភាសន៍អ្នកផ្ដល់ព័ត៌មានសំខាន់៖ ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្ដូរយេនឌ័រជាបុរស សមាជិកគ្រួសាររបស់ពួកគេ អាជ្ញាធរមូលដ្ឋាន និងអ្នកចូលរួមចំណែកថ្នាក់ជាតិទាំងអស់ដែលបានចូលរួមពង្រឹងភាពម្ចាស់ការរបស់អ្នកស្រលាញ់ភេទដូចគ្នា (LGBTIQ)។

## ៣.២. ឧបករណ៍ក្នុងការប្រមូលទិន្នន័យ

ក្រុមសិក្សាស្រាវជ្រាវនេះបានពិគ្រោះជាមួយអង្គការរ៉ក់ទាក់ទងនឹងឧបករណ៍ដែលប្រើសម្រាប់ការសម្ភាសន៍៖

- កម្រងសំនួរពាក់កណ្ដាលរៀបចំសម្រាប់សម្ភាសន៍ក្រុមស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្ដូរយេនឌ័រជាបុរស សមាជិកគ្រួសារ និងអ្នកចូលរួម(អាជ្ញាធររាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ភ្នាក់ងារសហប្រជាជាតិ) ដែលសរុបមាន ០៣ប្រភេទ។
- ការសម្ភាសន៍ទាំងអស់ត្រូវបានធ្វើឡើងជាភាសាខ្មែរ(លើកលែងតែការសម្ភាសន៍មួយជាមួយ តំណាងមកពីគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដែលចង់ឲ្យធ្វើការសម្ភាសន៍ជាភាសាអង់គ្លេស)។
- ឧបករណ៍ទាំងអស់នោះ ធ្វើឡើងដំបូងជាភាសាអង់គ្លេស សម្រាប់ពិគ្រោះជាមួយអង្គការរ៉ក់។ ក្រោយពីភាគីទាំងអស់យល់ព្រមលើឧបករណ៍ទាំងអស់នោះហើយ ក្រុមអ្នកស្រាវជ្រាវបានធ្វើការសាកល្បងចំនួន ០៤ដង ដើម្បីពិនិត្យមើលលើឧបករណ៍នោះ ដោយកាត់ឲ្យមានលក្ខណៈខ្លីជាមុន។

### ៣.៣. វិធីសាស្ត្រក្នុងការវិភាគទិន្នន័យនិងដំណើរការរបស់វា

ការសិក្សាស្រាវជ្រាវនេះ ក៏ត្រូវបានដាក់លេខកូដ ដើម្បីកំណត់ទិន្នន័យ នៅក្នុងដំណើរការវិភាគទិន្នន័យ។ វាឆ្លងកាត់ដំណាក់កាលជាច្រើន។ ព័ត៌មានរបស់អ្នកចូលរួមសំខាន់ដែលបានទទួល តាមរយៈការថតជាសម្លេង។ ការសិក្សាស្រាវជ្រាវនេះអនុវត្តការកំណត់កូដលើ ០៣កម្រិត៖

**កម្រិតទី១៖ ការវិភាគ៖** ដំណាក់កាលនេះមានគោលបំណងធ្វើឲ្យទិន្នន័យដែលមានលក្ខណៈរាយប៉ាយ មកជាមានរបៀបរៀបរយ ជាមួយនឹងការរៀបចំដ៏ត្រឹមត្រូវ។ ការកំណត់មួយគឺជាការប្រើប្រាស់ពាក្យ ឬពាក្យខ្លីមួយដែលសរុប ឬចាប់យកអត្ថន័យសំខាន់ នៃអ្វីដែលអ្នកផ្តល់ព័ត៌មានបាននិយាយ។ គោលបំណងនៃការធ្វើនេះ គឺដើម្បីបង្កើតឲ្យបានគោលគំនិតមូលដ្ឋាន ដែលត្រូវគ្នាជាមួយនឹងទិន្នន័យ។ នៅក្នុងការកំណត់ នេះ ការកំណត់កូដបើកត្រូវបានប្រើប្រាស់ដែល "កូដបើក" នៃការបំបែកទិន្នន័យនៅកន្លែងដែលសក្តិសម ដើម្បីដាក់ឲ្យវាត្រូវគ្នានៅជំហានបន្ទាប់។ ការឆ្លុះបញ្ចាំងនិងការពិភាក្សារបស់អ្នកសិក្សាស្រាវជ្រាវបានធ្វើនៅក្នុងដំណាក់កាលនេះ ដើម្បីកំណត់បញ្ហាចម្បង។

**កម្រិតទី២៖ ការកំណត់រៀបចំឡើងវិញ ហើយដាក់ចូលតាមប្រភេទ៖** ដំណាក់កាលនេះ គឺជាការអភិវឌ្ឍប្រភេទ។ ការកំណត់ប្រភេទនេះមានលក្ខណៈជាការវិភាគ(ជាជាងការរៀបរាប់)។ ការកំណត់ប្រភេទត្រូវបានធ្វើឡើងផ្អែកតាមការកំណត់ទី១ ដើម្បីកំណត់ឲ្យបាននូវរបកគំហើញដែលកើតឡើងនៅក្នុងសិក្សាការស្រាវជ្រាវ។ អ្នកដឹកនាំការស្រាវជ្រាវដែលបានអភិវឌ្ឍនិងរៀបចំប្រភេទសំខាន់ៗនៅក្នុងទំនាក់ទំនងជាមួយនឹងផ្នែកដែលពាក់ព័ន្ធ(អំពើហិង្សា វិធីសាស្ត្រដោះស្រាយ ផលប៉ះពាល់នៃអំពើហិង្សា និងឫសគល់នៃអំពើហិង្សា)។

**កម្រិតទី៣៖ របកគំហើញសំខាន់ៗដែលអភិវឌ្ឍចេញពីការវិភាគ៖** ក្រោយពីចាត់ចំណាត់ថ្នាក់ប្រភេទហើយ គេអាចកំណត់បានរបកគំហើញសំខាន់ៗ សម្រាប់ចំណុចនីមួយៗ។ របកគំហើញសំខាន់ៗ បានក្លាយជាមូលដ្ឋានសម្រាប់ការវិភាគចុងក្រោយ ក្នុងចំណោមអ្នកស្រាវជ្រាវជាមួយនឹងការណែនាំពី អ្នកដឹកនាំ អ្នកស្រាវជ្រាវ ហើយគេនឹងសរសេរពី ការសង្ខេបនៃរបកគំហើញនោះ ដោយផ្អែកតាមការបកស្រាយ និងការវិភាគនៃទិន្នន័យនោះ។ មធ្យោបាយនេះត្រូវបានអនុវត្តដោយសារតែការវិភាគទិន្នន័យនោះមានលក្ខណៈ ប្រព័ន្ធនិងមានការចូលរួម។ ក្រុមអ្នកស្រាវជ្រាវបានសង្ខេបក្រោយពីបានបញ្ចប់ការងារនៅខេត្តនីមួយៗ ហើយពិភាក្សានិងពិនិត្យមើលលើបញ្ហាសំខាន់ៗ នៅក្នុងខេត្តនីមួយៗ និងដាក់វាបញ្ចូលគ្នា។ ការធ្វើបែបនេះ បានធ្វើឲ្យរបាយការណ៍នេះ មានលក្ខណៈរឹងមាំ ដែលបានបង្ហាញយ៉ាងច្បាស់នូវភាពខុសគ្នាជាសារវន្ត នៅតាមខេត្តទាំងនោះ។

## ៤. ការពិចារណាលើក្រមសីលធម៌

តាមរយៈដំណើរការវាយតម្លៃ ក្រុមស្រាវជ្រាវតាមគោរពតាមគោលនយោបាយគាំពារនិងក្រមសីលធម៌របស់អង្គការសហគមន៍ឥន្ទធនូកម្ពុជាបានយ៉ាងតឹងរ៉ឹង។ អ្នកស្រាវជ្រាវបានអនុវត្តគោលការណ៍នានាដែលស្របតាមទស្សនវិស័យ បេសកកម្ម និងគុណតម្លៃរបស់អង្គការរ៉ក់ ព្រមទាំងធ្វើតាមបទដ្ឋានរបស់រ៉ក់នៅពេលទំនាក់ទំនងជាមួយសហគមន៍ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស។ រូបថតរបស់អ្នកចូលរួមសម្ភាសន៍ត្រូវបានថតនៅពេលដែលពួកគាត់បានអនុញ្ញាតិ ហើយគ្មានរូបថតណាមួយដែលបានប្រើ

ប្រាស់នៅក្នុងរបាយការណ៍នេះ ដោយគ្មានការអនុញ្ញាតិយល់ព្រម ពីអ្នកចូលរួមសម្ភាសន៍ សម្រាប់ការសិក្សាស្រាវជ្រាវនេះឡើយ។

មិនមានឈ្មោះពិតរបស់ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស ដែលបានផ្តល់បទសម្ភាសន៍ត្រូវបានប្រើប្រាស់សម្រាប់ធ្វើការប្រមូលនិងវិភាគទិន្នន័យនោះទេ ប៉ុន្តែប្រើឈ្មោះក្លែងក្លាយ ដោយអ្នកស្រាវជ្រាវបានសាកសួរអ្នកចូលរួមអំពីឈ្មោះដែលពួកគេពេញចិត្តដាក់។ មានអ្នកចូលរួមខ្លះបានអនុញ្ញាតឲ្យ ប្រើឈ្មោះពិតរបស់ខ្លួន ហើយអ្នកស្រាវជ្រាវបានកត់ត្រាចំណាំនូវឈ្មោះពិតទាំងនោះដើម្បីប្រើប្រាស់នៅក្នុងរបាយការណ៍។ សម្រាប់កំណត់ត្រានិងកូដវិភាគទិន្នន័យ គឺត្រូវបានប្រើប្រាស់ដោយការដាក់លេខសម្គាល់ ឧទាហរណ៍៖ “ST-LBT-TGM-KII23”។ មានតែអ្នកដឹកនាំការស្រាវជ្រាវប៉ុណ្ណោះបានរក្សាទុកបញ្ជីឈ្មោះពិត ឈ្មោះក្លែងក្លាយ និងលេខកូដច្បាប់ដើម។

បន្ទាប់ពីការសិក្សាស្រាវជ្រាវនេះត្រូវបានបញ្ចប់ ការថតសម្លេងនៃបទសម្ភាសន៍ និងកំណត់ត្រា(ជាភាសាអង់គ្លេស) ត្រូវបានប្រគល់ជូនដល់អង្គការរ៉ក់ ហើយសមាជិកក្រុមស្រាវជ្រាវលុបចោលនូវរាល់ព័ត៌មានទាំងអស់ដែលបានប្រមូលសម្រាប់ការសិក្សាស្រាវជ្រាវនេះ(រាប់បញ្ចូលទាំង កំណាត់ត្រាសរសេរដោយដៃ នៅលើកម្រងសំនួរនិងបទសម្ភាសន៍ជាសម្លេងដែលបានថត)។

### ៥. កម្រិតភាពនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវជាលក្ខណៈគុណភាពនេះមានគំរូតូច ដូច្នេះហើយវាមានឧបសគ្គនិងកម្រិតភាពដូចខាងក្រោម៖

- អ្នកចូលរួមភាគច្រើនសម្រាប់ការសិក្សាស្រាវជ្រាវនេះ គឺជាសមាជិករបស់អង្គការសហគមន៍ឥន្ទធនូកម្ពុជា ដូច្នេះហើយពួកគេមាន “សំណាញ់សុវត្ថិភាព” ដែលពួកគេអាចចែករំលែកនិងប្តូរភាពឈឺចាប់និងសេចក្តីព្រួយបារម្ភរបស់ខ្លួនបាន។ នៅក្នុងស្ថានភាពពិត គ្មានតួលេខ ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស ដែលបានទាក់ទងបណ្តាញនានា ដូច្នេះហើយពួកគេអាចរស់នៅដោយផ្តាច់ខ្លួនឆ្ងាយពីគេឯង។ ប៉ុន្តែការសិក្សាស្រាវជ្រាវនេះមិនអាចធ្វើការចងក្រងរឿងរ៉ាវផ្ទាល់ខ្លួនបាននោះទេ។
- ក្រុមស្រាវជ្រាវមិនបានជួយសម្ភាសន៍ជាមួយឪពុកម្តាយដែលប្រើអំពើហិង្សាលើកូនដែលជាស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសទេ។ ឪពុកម្តាយទាំងអស់ត្រូវបានណែនាំដោយបណ្តាញសមាជិករបស់អង្គការរ៉ក់។ ដូច្នេះ ពួកគាត់បានបើកចំហរ និងទទួលយកកូនៗក្នុងភាពជាខ្លួនគេ។
- ការសិក្សាស្រាវជ្រាវនេះបានកំណត់ភាពខុសគ្នារវាងស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស ដែលមានវ័យចំណាស់និងវ័យក្មេង(អាយុក្រោម ៣៥ឆ្នាំ) សម្រាប់បទពិសោធន៍នៃអំពើហិង្សាគ្រួសាររបស់ពួកគាត់។ ប៉ុន្តែ ការប្រៀបធៀបនូវការកំណត់មូលហេតុមិនអាចធ្វើទៅបាន

នោះទេ ដោយសារតែ គំរូនៃការសិក្សាស្រាវជ្រាវនេះមាន ចំនួនតិចតួចពេក(សរុបចំនួន៦១នាក់LBT មានអាយុក្រោម ៣៥ឆ្នាំស្មើនឹង ៥០% ឬ ចំនួន ៣០នាក់)។

- ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស ដែលបានចូលរួមផ្តល់បទសម្ភាសន៍ព្យាយាមការពារឪពុកម្តាយរបស់ខ្លួន ដោយការស្តីបន្ទោសឲ្យខ្លួនឯងថា ពួកគាត់បង្កបញ្ហាដល់ក្រុមគ្រួសារ ដូចនេះហើយ តួលេខ(ប្រេវ៉ាឡង់)នៃការអំពើហិង្សាលើរូបរាងកាយអាចមានច្រើន។
- ប្រមាណជា ៩០% នៃប្រជាជនកម្ពុជាគឺជាពុទ្ធសាសនិក ហើយ១០% ទៀត គឺជាគ្រឹស្តិបរិស័ទ ឥស្លាម និងសាសនាដទៃទៀត។ ជនជាតិភាគតិចផ្សេងៗក្នុងចំណោមជនជាតិខ្មែរភាគច្រើនរួមមាន ទាំងជនជាតិវៀតណាម ចិន និងជនជាតិឯទៀត (ដែលភាគច្រើនរស់នៅភូមិភាគឦសាន)។ ប៉ុន្តែ ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរសភាគច្រើនដែលបានចូលរួម នៅក្នុងការសិក្សាស្រាវជ្រាវនេះបានកំណត់ខ្លួនឯងថាជាជនជាតិខ្មែរនិងពុទ្ធសាសនិក។ មានអ្នកចូលរួមផ្តល់សម្ភាសន៍តែម្នាក់គត់ដែលបានកំណត់ខ្លួនឯងជាជនជាតិខ្មែរ-ចិន។ ហេតុដូចនេះ អន្តរទំនាក់ទំនងនៃការរើសអើងនិងអំពើហិង្សាផ្អែកលើជាតិសាសន៍និងសាសនាមិនត្រូវបាន វែកញែកស៊ីជម្រៅឡើយ។
- អំពើហិង្សានៅតំបន់ទីក្រុងនិងទីជនបទអាចមានសភាពខុសគ្នា។ ប៉ុន្តែ នៅប៉ុន្មានទសវត្សចុងក្រោយនេះដោយសារកត្តាចំណាកស្រុកជាញឹកញយកើតឡើងនៅក្នុងសង្គមកម្ពុជា ធ្វើឱ្យការប្រៀបធៀបមានការពិបាក។

ទំនាក់ទំនង អង្គការសហគមន៍ឥន្ទធនូកម្ពុជា(រ៉ក់)
ផ្ទះលេខ ៤៧E1 ផ្លូវ៣៥០ សង្កាត់បឹងកេងកងIII ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
លេខទូរស័ព្ទ ៖ (+៨៥៥)១២ ៤៨១ ៥៦១ /(+៨៥៥)៩០ ៨៧៥ ៩២៩
អ៊ីម៉ែល ៖ contact@rockcambodia.org
គេហៈទំព័រ ៖ www.rockcambodia.org
គេហៈទំព័រហ្វេសប៊ុក ៖ Facebook.com/RoCKMERLGBT2009

ឧបត្ថម្ភដោយ៖
IWDA INTERNATIONAL WOMEN'S DEVELOPMENT AGENCY